ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ៩ លេខ ៨៥ សប្តាហ៍ទី ៣ ថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ២០០៩

រាជកិច្ច

ផ្សាយចេញពី

ទីស្ដីការគណៈរដ្ឋមន្ត្រី

តម្លៃលក់

១ ច្បាប់	៥.០០០ រៀល
១ ខែ	៤០.០០០ រៀល
៣ ខែ	១២០.០០០ រៀល
៦ ខែ	២៤០.០០០ រៀល
១២ ខែ	៤៨០.០០០ រៀល

(ត្រូវបង់តម្លៃជាមុន)

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្ដីសម្រេច សារាចរ ប្រកាស

ក

មាតិកា

I_ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

១_ព្រះរាជក្រម

២២-១០-២០០៩ -ព្រះរាជក្រម នស/រកម/១០០៩/០២១ ស្តីពីការប្រកាសឱ្យប្រើ ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ស្តីពីពាណិជ្ជកម្ម សេវាកម្ម ក្រោមកិច្ចព្រមព្រៀងក្របខណ្ឌ ស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងរដ្ឋាភិបាល នៃប្រទេសសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និង សាធារណរដ្ឋកូរ៉េ ៨៤៦៨

២_ព្រះរាជក្រឹត្យ

១៤-១០-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១០០៩/៩៩២ ស្តីពីការផ្តល់សញ្ជាតិខ្មែរ ដោយអាពាហ៍ពិពាហ៍ដល់លោក ជូលៀន ហែនសិន (JULIAN HANSEN) ជនជាតិណូវែលសេឡង់ សញ្ជាតិណូវែលសេឡង់ កើតនៅហែនឌឺសុន ប្រទេស ណូវែលសេឡង់ ៨៥៦៧

១៤-១០-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១០០៩/៩៩៣ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ញាតូបនីយកម្មដល់លោក អ៊ុង ប៊ីហួត (ONG BEE HUAT) ជនជាតិសិង្ហបុរី សញ្ជាតិសិង្ហបុរី កើតនៅប្រទេសសិង្ហបុរី ៨៥៦៨

១៩-១០-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១០០៩/១០០៨ ស្តីពីការតែងតាំងលោក យី គឹមលន់ ជាឧកញ៉ា ៨៥៦៩

២៧-១០-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១០០៩/១០២០ ស្តីពីការតម្លើងថ្នាក់មួយថ្នាក់ ក្នុងឋានន្តរស័ក្តិឧត្តមអភិបាល ជូនមន្ត្រីរាជការក្របខ័ណ្ឌអគ្គលេខាធិការដ្ឋានរដ្ឋសភា នៃមន្ត្រីរាជការក្រុមនីតិប្បញ្ញត្តិ ចំនួន ០៩ រូប ៨៥៧០

៣០-១០-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១០០៩/១០៣៥ ស្តីពីការតែងតាំងលោក ហុង ឆាយ ជាឧកញ៉ា ៨៥៧២

៣០-១០-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១០០៩/១០៣៦ ស្តីពីការតែងតាំងឯកឧត្តម តើ សែនសាខ ជាអនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និង កីឡា ៨៥៧៣

៣០-១០-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១០០៩/១០៣៧ ស្តីពីការតម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ទោ ជូនឧត្តមសេនីយ៍ត្រី ឈឹម សាខន នាយនគរបាលជាតិជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ៨៥៧៤

II_រាជរដ្ឋាភិបាល

១_អនុក្រឹត្យ

៣១-១០-២០០៩ -អនុក្រឹត្យលេខ ១៥៩៧ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិ នាយទាហាន ៨៥៧៥

០៤-១១-២០០៩ -អនុក្រឹត្យលេខ ១៦០១ អនក្រ.បក ស្តីពីការជូនមេដាយសហមេត្រី ៨៥៧៧
០៤-១១-២០០៩ -អនុក្រឹត្យលេខ ១៦០២ អនក្រ.បក ស្តីពីការជូនមេដាយការងារ ៨៥៧៨
១០-១១-២០០៩ -អនុក្រឹត្យលេខ ១៦០៣ អនក្រ.បក ស្តីពីការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ៨៥៨១
១០-១១-២០០៩ -អនុក្រឹត្យលេខ ១៦០៤ អនក្រ.បក ស្តីពីការជូនមេដាយមាសការងារ ៨៥៨៣

២.សេចក្តីសម្រេច

១២-១១-២០០៩ -សេចក្តីសម្រេចលេខ ៦៨ សសរ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសម្របសម្រួល និង ដោះស្រាយបញ្ហាវិវាទនៅក្នុងគម្រោងវិនិយោគអភិវឌ្ឍន៍ របស់ក្រុមហ៊ុន UNION DEVELOPMENT GROUP Co.,Ltd ខេត្តកោះកុង ៨៥៨៥

III.ការងារបណ្តាក្រសួង

ទីស្តីការគណៈរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៨-១០-២០០៩ -សេចក្តីជូនដំណឹងលេខ ០១២ សហវ.អពដ ស្តីពីវិធានការបំបាត់ការលួចបន្លំបោះពុម្ព ការធ្វើអាជីវកម្មជួញដូរ និង ការប្រើប្រាស់ប័ណ្ណក្លែងក្លាយ សំរាប់បង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ ឆ្នាំ ២០០៩ ៨៥៨៨

ព្រះរាជក្រម

នស/រកម/១០០៩/០២១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ស្តីពីពាណិជ្ជកម្មសេវាកម្ម ក្រោមកិច្ចព្រមព្រៀងក្របខណ្ឌ ស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ រវាងរដ្ឋាភិបាលនៃប្រទេសសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋកូរ៉េ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៤ និងដែលព្រឹទ្ធសភាពុំមានពេលវេលាគ្រប់គ្រាន់អាចពិនិត្យ និងឱ្យយោបល់ក្នុងរយៈពេលកំណត់ក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញបានឡើយ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

ច្បាប់

ស្តីពី

ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មសេវាកម្ម ក្រោមកិច្ចព្រមព្រៀងក្របខណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងរដ្ឋាភិបាលនៃប្រទេសសមាជិក សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋកូរ៉េ

មាត្រា ១.–

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មសេវាកម្ម ក្រោមកិច្ចព្រមព្រៀងក្របខណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ រវាងរដ្ឋាភិបាលនៃប្រទេសសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋកូរ៉េ ដែលបានចុះហត្ថលេខានៅសឹង្ហបុរី នាថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

មាត្រា ២.–

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

មាត្រា ៣.–

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី២៦ ខែ តុលា ឆ្នាំ ២០០៩

នស/រកម.១០០៩.០៣៣

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋមន្ត្រីស្តីទី

ហត្ថលេខា

គឹម ស៊ីថុន

លេខ ៩៥៥ ច.ល
ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ខែ ១១ ឆ្នាំ២០០៩
ទីស្តីការគណៈរដ្ឋមន្ត្រី

ជិនកេន

កិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មសេវាកម្ម ក្រោមកិច្ចព្រមព្រៀងក្របខណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ រវាងរដ្ឋាភិបាលនៃប្រទេសសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋកូរ៉េ

រដ្ឋាភិបាលប្រ៊ុយណេដារូស្សាឡាម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសឹង្ហបុរី រាជាណាចក្រថៃឡង់ដ៍[១] និងសាធារណរដ្ឋសង្គមនិយមវៀតណាម, ជាប្រទេសសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋកូរ៉េ

ដោយរំលឹកឡើងវិញ នូវកិច្ចព្រមព្រៀងក្របខណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ រវាងរដ្ឋាភិបាលនៃប្រទេសសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋកូរ៉េ (កិច្ចព្រមព្រៀងក្របខណ្ឌ) ដែលបានចុះហត្ថលេខានៅទីក្រុងកូឡាឡាំពួ ប្រទេសម៉ាឡេស៊ី នាថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៥

ដោយរំលឹកថែមទៀត នូវមាត្រា១.៣ និង២.២ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌដែលឆ្លុះបញ្ចាំងអំពីការប្តេជ្ញារបស់ខ្លួនក្នុងការបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ ដែលគ្របដណ្តប់លើពាណិជ្ជកម្មសេវាកម្ម ។

ដោយកត់សំគាល់ នូវកម្មវត្ថុនៃកិច្ចព្រមព្រៀងក្របខណ្ឌ ដើម្បីបង្កើនសហប្រតិបត្តិការសេដ្ឋកិច្ច និងសមាហរណកម្មសេដ្ឋកិច្ចឱ្យកាន់តែស៊ីជំរៅរវាងប្រទេសទាំងនោះ តាមរយៈសេរីភាវូបនីយកម្មពាណិជ្ជកម្មសេវាកម្មជាបណ្តើរៗ ដោយអនុលោមតាមមាត្រា V នៃកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម (GATS) ។

អះអាងសារជាថ្មី អំពីការប្តេជ្ញាអនុវត្តសេរីភាវូបនីយកម្មពាណិជ្ជកម្មសេវាកម្មរវាងប្រទេសសមាជិកអាស៊ាន និងសាធារណរដ្ឋកូរ៉េ ដោយគ្របដណ្តប់លើវិស័យស្ទើរតែទាំងអស់ ដោយយកមកពិចារណាអំពីវិស័យវេទយិតភាពរបស់បណ្តាភាគី និងជាមួយនឹងការផ្តល់ប្រព្រឹត្តិកម្មពិសេស និងដោយឡែក ចំពោះប្រទេសសមាជិកអាស៊ាន និងផ្តល់ភាពទន់ភ្លន់បន្ថែមសំរាប់ប្រទេសសមាជិកអាស៊ានថ្មី រួមមាន ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ សហភាពមីយ៉ាន់ម៉ា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ។

---

[១] សម្រាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ រាជាណាចក្រថៃឡង់ដ៍ចូលរួមក្នុងក្រុមនេះបានតែនៅពេលណាដែលហត្ថលេខាពាក់ព័ន្ធនានារបស់ថៃឡង់ដ៍ត្រូវបានដាក់ភ្ជាប់ជាឧបសម្ព័ន្ធរួចសិន ។

ដោយមានបំណងប្រាថ្នាដើម្បី បង្កើនសហប្រតិបត្តិការនៅក្នុងវិស័យសេវាកម្មរវាងប្រទេសទាំងនោះ សំដៅបង្កើនប្រសិទ្ធភាព និងភាពប្រកួតប្រជែង ព្រមទាំងដើម្បីធ្វើពិពិធកម្មការផ្គត់ផ្គង់ និងចែកចាយសេវានៃអ្នកផ្គត់ផ្គង់សេវានៃបណ្តាភាគី និង

ដោយទទួលស្គាល់ នូវសិទ្ធិរបស់បណ្តាភាគីក្នុងការនិយ័ត និងដាក់ឱ្យអនុវត្តបទបញ្ញត្តិថ្មីៗសំរាប់ការផ្គត់ផ្គង់សេវានៅក្នុងដែនដីរបស់ពួកគេ ដើម្បីសំរេចនូវគោលបំណងនយោបាយជាតិ និងដោយសារភាពខុសគ្នានៃកំរិតអភិវឌ្ឍន៍បទប្បញ្ញត្តិសេវាកម្មនានារបស់បណ្តាភាគី និងតំរូវការពិសេសរបស់បណ្តាភាគីក្នុងការអនុវត្តសិទ្ធិនេះ.

បានព្រមព្រៀងដូចតទៅ :

ជំពូក I
និយមន័យ និងវិសាលភាព

មាត្រា ១
និយមន័យ

សំរាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ

(ក) AEM មានន័យថា រដ្ឋមន្ត្រីសេដ្ឋកិច្ចប្រទេសសមាជិកអាស៊ាន

(ខ) **សេវាជួសជុល និងថែទាំអាកាសយាន** មានន័យថា សកម្មភាពទាំងឡាយដែលធ្វើឡើងចំពោះអាកាសយាន ឬផ្នែកនៃអាកាសយាន នៅពេលដែលអាកាសយាននោះមិនហោះហើរ និងមិនរួមបញ្ចូល សេវាថែទាំជាប្រចាំឡើយ

(គ) **អាស៊ាន** មានន័យថា សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ រួមមាន ប្រ៊ុយណេដារូស្សាឡាម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី រាជាណាចក្រថៃឡង់ដ៏ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ។

(ឃ) **តំបន់ពាណិជ្ជកម្មសេរី អាស៊ាន-កូរ៉េ** មានន័យថា តំបន់ពាណិជ្ជកម្មសេរី អាស៊ាន-កូរ៉េ ដែលបាន បង្កើតឡើងដោយកិច្ចព្រមព្រៀងក្របខ័ណ្ឌ និងកិច្ចព្រមព្រៀងពាក់ព័ន្ធផ្សេងទៀត ដែលមានចែងនៅក្នុងកថាខណ្ឌ១ នៃមាត្រា១.៤ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ

(ង) **បណ្តាប្រទេសសមាជិកអាស៊ាន** មានន័យថា ប្រ៊ុយណេដារូស្សាឡាម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសឹង្ហបុរី រាជាណាចក្រថៃឡង់ដ៏ និងសាធារណរដ្ឋសង្គមនិយមវៀតណាម

(ច) **ប្រទេសសមាជិកអាស៊ាន** មានន័យថា ប្រ៊ុយណេដារូស្សាឡាម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសឹង្ហបុរី រាជាណាចក្រថៃឡង់ដ៏ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ។

(ឆ) **វត្តមានពាណិជ្ជកម្ម** មានន័យថា ជាប្រភេទធុរកិច្ច ឬការបង្កើតវិជ្ជាជីវៈណាមួយ រួមបញ្ចូលទាំង:

(i) ការបង្កើត, ការទទួលបាន ឬ ការរក្សានីតិបុគ្គលដែលមានស្រាប់ ឬ

(ii) ការបង្កើត ឬការរក្សាប្រើប្រាស់សាខាក្រុមហ៊ុន ឬការិយាល័យតំណាង

នៅក្នុងដែនដីនៃភាគីមួយ សំរាប់គោលបំណងនៃការផ្គត់ផ្គង់សេវាមួយ ។

(ជ) **សេវាប្រព័ន្ធផ្ទុកពត៌មានដោយកុំព្យូទ័រ** (CRS) មានន័យថា ជាសេវាផ្តល់ដោយប្រព័ន្ធកុំព្យូទ័រ ផ្ទុកនូវពត៌មានស្តីពីកាលវិភាគហោះហើររបស់យន្តហោះ, ភាពទំនេររបស់យន្តហោះ តម្លៃសំបុត្រយន្តហោះ និងវិធានបង់ថ្លៃសំបុត្រយន្តហោះ ដែលតាមរយៈនេះ សំបុត្រយន្តហោះអាចត្រូវបានកក់ ឬចេញពុម្ពបាន ។

(ឈ) **ពន្ធផ្ទាល់** រួមបញ្ចូលនូវប្រភេទពន្ធទាំងអស់លើចំណូលសរុប លើមូលធនសរុប ឬលើសមាសធាតុចំណូល ឬមូលធន រួមមាន ពន្ធលើចំណូលពីការផ្ទេរកម្មសិទ្ធិទ្រព្យសម្បត្តិ ពន្ធលើអចលនទ្រព្យ មរតក និងអំណោយ និងពន្ធលើបរិមាណសរុបនៃប្រាក់ឈ្នួល ឬប្រាក់បៀវត្ស ដែលបើកដោយសហគ្រាសនានា ព្រមទាំងពន្ធលើកំណើនមូលធន ។

(ញ) **កិច្ចព្រមព្រៀងក្របខ័ណ្ឌ** មានន័យថា កិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយរវាងរដ្ឋាភិបាលនៃប្រទេសសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋកូរ៉េ ។

(ជ) GATS មានន័យថា កិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម ដែលមាននៅក្នុងឧបសម្ព័ន្ធ 1B នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក ។

(ឋ) **គណៈកម្មាធិការអនុវត្តន៍** មានន័យថា គណៈកម្មាធិការទទួលបន្ទុកអនុវត្ត ដែលបានបង្កើតឡើងនៅក្រោមមាត្រា ៩.៣ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ

(ឌ) **នីតិបុគ្គល** មានន័យថា នីតិបុគ្គលណាមួយ ដែលត្រូវបានបង្កើត ឬរៀបចំឡើងក្រោមច្បាប់ជាធរមាន ទោះបីជាដើម្បីរកប្រាក់ចំណេញ ឬក្នុងគោលបំណងដទៃទៀតក្តី និងទោះបីជាកម្មសិទ្ធិរបស់ឯកជន ឬកម្មសិទ្ធិរបស់រដ្ឋាភិបាលក្តី ដែលរួមមាន សាជីវកម្ម ក្រុមហ៊ុនទទួលភារៈគ្រប់គ្រង ក្រុមហ៊ុនសហកម្មសិទ្ធិ ក្រុមហ៊ុនចំរុះទុន សហគ្រាសឯកកម្មសិទ្ធិ ឬ សមាគម ។

(ឍ) **នីតិបុគ្គលរបស់ភាគីមួយទៀត** មានន័យថា នីតិបុគ្គលដែល:

(i) ត្រូវបានបង្កើត ឬរៀបចំឡើងនៅក្រោមច្បាប់របស់ភាគីផ្សេងទៀត និងចូលរួមក្នុងប្រតិបត្តិការធុរកិច្ចជាដុំកំភួន នៅក្នុងដែនដីរបស់ភាគីនោះ ឬភាគីដទៃទៀត ឬ

(ii) ក្នុងករណីនៃការផ្គត់ផ្គង់សេវាតាមរយៈវត្តមានពាណិជ្ជកម្ម ការកាន់កាប់កម្មសិទ្ធិ ឬ ការគ្រប់គ្រងដោយ:

១. រូបវន្តបុគ្គលនៃភាគីនោះ ឬ

២. នីតិបុគ្គលនៃភាគីដទៃទៀត ដែលបានបង្ហាញនៅក្នុងកថាខណ្ឌរង (i)

(ណ) **នីតិបុគ្គល :**

(i) **ត្រូវបានកាន់កាប់កម្មសិទ្ធិ** ដោយបុគ្គលទាំងឡាយនៃភាគីមួយ ប្រសិនបើលើសពី៥០ ភាគរយនៃភាគទុនរបស់ក្រុមហ៊ុន ត្រូវបានកាន់កាប់សិទ្ធិដោយបុគ្គលទាំងឡាយនៃភាគីនោះ

(ii) **ត្រូវបានគ្រប់គ្រង** ដោយបុគ្គលទាំងឡាយនៃភាគីមួយ ប្រសិនបើបុគ្គលនោះមានអំណាចតែងតាំងសមាសភាពនាយកភាគច្រើនរបស់ខ្លួន ឬមានសិទ្ធិតាមផ្លូវច្បាប់ ក្នុងការបញ្ជាឱ្យអនុវត្តសកម្មភាពរបស់ខ្លួន

(iii) **ត្រូវបានចងសម្ព័ន្ធ** ជាមួយបុគ្គលម្នាក់ផ្សេងទៀត នៅពេលដែលបុគ្គលនោះគ្រប់គ្រង ឬ ត្រូវបានគ្រប់គ្រងដោយបុគ្គលម្នាក់ផ្សេងទៀត ឬនៅពេលដែលបុគ្គលនោះ និងបុគ្គលម្នាក់ផ្សេងទៀត ត្រូវបានគ្រប់គ្រងដូចគ្នាដោយបុគ្គលតែមួយ

(ត) **កូរ៉េ** មានន័យថា សាធារណរដ្ឋកូរ៉េ

(ថ) **វិធានការ** មានន័យថា វិធានការណាមួយដែលធ្វើឡើងដោយភាគីមួយ ទោះជាក្នុងទំរង់ជាច្បាប់ បទប្បញ្ញត្តិ វិធាន នីតិវិធី សេចក្តីសំរេច វិធានការរដ្ឋបាល ឬទំរង់ផ្សេងទៀត

(ទ) **វិធានការចាត់ឡើងដោយបណ្តាភាគី** មានន័យថា ជាវិធានការនានាដែលធ្វើឡើងដោយ:

(i) រដ្ឋាភិបាល និងអាជ្ញាធរថ្នាក់កណ្តាល តំបន់ ឬ មូលដ្ឋាន និង

(ii) អង្គការក្រៅរដ្ឋាភិបាលនានា ដែលប្រើប្រាស់អំណាចប្រតិភូកម្មដោយរដ្ឋាភិបាល ឬ អាជ្ញាធរថ្នាក់កណ្តាល តំបន់ ឬមូលដ្ឋាន។

(ធ) **វិធានការចាត់ឡើងដោយបណ្តាសមាជិក ដែលជះឥទ្ធិពលដល់ពាណិជ្ជកម្មសេវាកម្ម** រួមបញ្ចូលនូវវិធានការនានាចំពោះ:

(i) ការទិញ ទូទាត់ ឬប្រើប្រាស់សេវា

(ii) សិទ្ធិចូលរួម និងប្រើប្រាស់ ទាក់ទិននឹងការផ្គត់ផ្គង់សេវា សេវាដែលតម្រូវដោយបណ្តាភាគីសំរាប់ផ្គត់ផ្គង់ដល់សាធារណជនជាទូទៅ

(iii) វត្តមាន រួមបញ្ចូល វត្តមានពាណិជ្ជកម្ម វត្តមានបុគ្គលមកពីភាគីម្ខាង ដើម្បីផ្គត់ផ្គង់សេវានៅក្នុងដែនដីនៃភាគីម្ខាងទៀត

(ន) **អ្នកផ្គត់ផ្គង់សេវាផ្តាច់មុខ** គឺជាបុគ្គល សាធារណៈ ឬឯកជន នៅក្នុងទីផ្សារពាក់ព័ន្ធនៃដែនដីរបស់ភាគីមួយ ដែលត្រូវបានអនុញ្ញាត ឬបានបង្កើតឡើងជាផ្លូវការ ឬជាឥទ្ធិពល ដោយភាគីនោះ ក្នុងរូបភាពជាអ្នកផ្គត់ផ្គង់ផ្តាច់មុខនូវសេវាប្រភេទនោះ

(ប) **រូបវ័ន្តបុគ្គលនៃភាគីមួយផ្សេងទៀត** មានន័យថា រូបវ័ន្តបុគ្គលដែលស្នាក់អាស្រ័យនៅក្នុងដែនដីរបស់ភាគីផ្សេងទៀត ឬស្នាក់អាស្រ័យនៅកន្លែងផ្សេង និងអ្នកដែលស្ថិតនៅក្រោមច្បាប់ នៃភាគីផ្សេងទៀតនោះ :

(i) ជាជនជាតិនៃភាគីដទៃទៀតនោះ ឬ

(ii) មានសិទ្ធិស្នាក់នៅអចិន្ត្រៃយ៍ [២] ក្នុងដែនដីភាគីដទៃទៀតនោះ ក្នុងករណីដែលភាគីមួយផ្តល់ប្រព្រឹត្តិកម្មចំពោះអ្នកស្នាក់នៅអចិន្ត្រៃយ៍ស្ទើរតែដូចគ្នាទាំងស្រុងនឹងប្រព្រឹត្តិកម្មដែលផ្តល់ចំពោះជនជាតិខ្លួន ពាក់ព័ន្ធនឹងវិធានការដែលជះឥទ្ធិពលដល់ពាណិជ្ជកម្មសេវាកម្ម ដូចបានជូនដំណឹងទៅក្នុងការទទួលយក ឬការចូលជាភាគីនៃកិច្ចព្រមព្រៀងនេះ ឱ្យតែពុំមានភាគីណាមួយត្រូវបានដាក់កាតព្វកិច្ចឱ្យផ្តល់ចំពោះអ្នកមានសិទ្ធិស្នាក់នៅអចិន្ត្រៃយ៍នូវប្រព្រឹត្តិកម្មដែលមានភាពអនុគ្រោះច្រើនជាងប្រព្រឹត្តិកម្មដែលត្រូវផ្តល់ដោយភាគីដទៃទៀតនោះ ចំពោះអ្នកស្នាក់នៅអចិន្ត្រៃយ៍ទាំងនេះឡើយ ។ សេចក្តីជូនដំណឹងបែបនេះ ត្រូវរួមបញ្ចូលនូវការធានា ចំពោះអ្នកស្នាក់នៅអចិន្ត្រៃយ៍ទាំងនោះឱ្យអនុលោមជាមួយច្បាប់ និងបទប្បញ្ញត្តិនានារបស់ខ្លួន ដូចគ្នានឹងការទទួលខុសត្រូវដែលភាគីដទៃទៀតប្រកាន់យកចំពោះពលរដ្ឋរបស់ខ្លួនដែរ

(រ) **ប្រទេសសមាជិកអាស៊ានថ្មី** មានន័យថា ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ។

(ល) **បណ្តាភាគី** មានន័យថា ហៅកាត់ថា បណ្តាប្រទេសសមាជិកអាស៊ាន និងកូរ៉េ

(វ) **ភាគី** មានន័យថា ប្រទេសសមាជិកអាស៊ានមួយ ឬ កូរ៉េ

(ស) **បុគ្គល** មានន័យថា រូបវន្តបុគ្គល ឬនីតិបុគ្គល

(ហ) **វិស័យ** សេវាកម្មមួយ មានន័យថា

(i) សំដៅដល់ការសន្យាតាមវិស័យមួយ ដែលមានអនុវិស័យសេវាមួយ ឬច្រើន ឬទាំងអស់នៃសេវាកម្មមួយនោះ ដូចមានចែងនៅក្នុងតារាងនៃការសន្យារបស់ភាគីមួយ

(ii) ក្រៅពីនេះ វិស័យសេវាកម្មទាំងមូលនោះ រួមបញ្ចូលទាំងអនុវិស័យទាំងអស់របស់វាផងដែរ

---

[២] បណ្តាភាគីអាចធ្វើការបំរុងចំពោះសិទ្ធិស្នាក់នៅអចិន្ត្រៃយ៍ក្នុងតារាងនៃការសន្យារបស់ខ្លួនក្រោមកិច្ចព្រមព្រៀងនេះ ឱ្យតែការបំរុងទាំងនោះមិនធ្វើឱ្យខូចខាតដល់សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីនៅក្នុងកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម (GATS) ។

(កក) **ការលក់ និងស្វែងរកទីផ្សារសេវាដឹកជញ្ជូនផ្លូវអាកាស** មានន័យថា ជាឱកាសនានាសំរាប់ក្រុមហ៊ុនអាកាសចរក្នុងការលក់ និងផ្តល់សេវាដឹកជញ្ជូនផ្លូវអាកាសដោយសេរីនៅក្នុងទីផ្សារ ដែលរួមមានគ្រប់ទិដ្ឋភាពទាំងអស់នៃការស្វែងរកទីផ្សារ ដូចជា ការស្រាវជ្រាវទីផ្សារ ផ្សាយពាណិជ្ជកម្ម និងចែកចាយ។ សកម្មភាពទាំងនេះ មិនរួមបញ្ចូលនូវការកំណត់ថ្លៃសេវាដឹកជញ្ជូនផ្លូវអាកាស និងលក្ខខណ្ឌអនុវត្តនានាឡើយ

(ខខ) **សេវាកម្ម** រួមបញ្ចូលនូវសេវាណាមួយនៅក្នុងវិស័យណាមួយ ដោយលើកលែងតែសេវាដែលផ្គត់ផ្គង់សំរាប់អនុវត្តន៍កិច្ចការរបស់អាជ្ញាធររដ្ឋាភិបាលចេញ

(គគ) **សេវាមួយដែលផ្គត់ផ្គង់សំរាប់អនុវត្តកិច្ចការរបស់អាជ្ញាធររដ្ឋាភិបាល** មានន័យថា សេវាណាមួយដែលផ្គត់ផ្គង់ដោយមិនផ្អែកលើមូលដ្ឋានពាណិជ្ជកម្ម ឬមិនប្រកួតប្រជែងជាមួយអ្នកផ្គត់ផ្គង់សេវាមួយ ឬច្រើន ទៀត។

(ឃឃ) **អ្នកប្រើប្រាស់សេវា** គឺបុគ្គលទាំងឡាយដែលទទួល ឬប្រើប្រាស់សេវាមួយ

(ងង) **សេវារបស់ភាគីដទៃទៀត"** មានន័យថា សេវាមួយដែលត្រូវបានផ្គត់ផ្គង់:

(i) មកពី ឬ នៅក្នុងដែនដីរបស់ភាគីដទៃទៀត ឬ នៅក្នុងករណីដឹកជញ្ជូនផ្លូវសមុទ្រ ត្រូវបានផ្គត់ផ្គង់តាមរយៈនាវាដែលបានចុះបញ្ជីក្រោមច្បាប់របស់ភាគីដទៃទៀតនោះ ឬ ដោយបុគ្គលនៃភាគីដទៃទៀតនោះ ដែលផ្គត់ផ្គង់សេវាតាមរយៈប្រតិបត្តិការនាវា និង/ ឬ ប្រើប្រាស់ទាំងស្រុង ឬដោយផ្នែកនូវប្រតិបត្តិការនាវានោះ ឬ

(ii) ក្នុងករណីនៃការផ្គត់ផ្គង់សេវាតាមរយៈវត្តមានពាណិជ្ជកម្ម ឬតាមរយៈវត្តមានរូបវន្តបុគ្គល ដោយអ្នកផ្គត់ផ្គង់សេវានៃភាគីដទៃទៀតនោះ

(ចច) **អ្នកផ្គត់ផ្គង់សេវា** មានន័យថា បុគ្គលណាម្នាក់ដែលធ្វើការផ្គត់ផ្គង់សេវា [៣]

(ឆឆ) **ការផ្គត់ផ្គង់សេវាមួយ** រួមបញ្ចូលនូវ ផលិតកម្ម ការចែកចាយ ការស្វែងរកទីផ្សារ ការលក់ និងការផ្តល់សេវា

---

[៣] នៅទីណាដែលសេវាមិនត្រូវបានផ្គត់ផ្គង់ផ្ទាល់ដោយនីតិបុគ្គល ប៉ុន្តែតាមរយៈទំរង់ផ្សេងៗនៃក្រុមហ៊ុនពាណិជ្ជកម្ម ដូចជាសាខា ឬ ការិយាល័យតំណាង អ្នកផ្គត់ផ្គង់សេវា (មានន័យថា នីតិបុគ្គល) តាមរយៈវត្តមានក្រុមហ៊ុននេះនឹងទទួលបានប្រព្រឹត្តិកម្មសំរាប់ផ្តល់ជូនអ្នកផ្គត់ផ្គង់សេវានៅក្រោមកិច្ចព្រមព្រៀងនេះ។ ប្រព្រឹត្តិកម្មបែបនេះ ត្រូវផ្តល់ចំពោះទីកន្លែងដែលក្រុមហ៊ុនធ្វើការផ្គត់ផ្គង់សេវា និងមិនត្រូវផ្តល់ចំពោះការផ្គត់ផ្គង់សេវាដទៃទៀតរបស់អ្នកផ្គត់ផ្គង់សេវាដែលស្ថិតនៅក្រៅដែនដីឡើយ ។

(ជជ) **ពាណិជ្ជកម្មសេវាកម្ម** ត្រូវបានកំណត់ថា ជាការផ្គត់ផ្គង់សេវាៈ

(i) ពីដែនដីនៃភាគីមួយ ទៅក្នុងដែនដីនៃភាគីណាមួយផ្សេងទៀត

(ii) នៅក្នុងដែនដីនៃភាគីមួយទៅអ្នកប្រើប្រាស់សេវានៃភាគីណាមួយផ្សេងទៀត;

(iii) ធ្វើឡើងដោយអ្នកផ្គត់ផ្គង់សេវានៃភាគីមួយ តាមរយៈវត្តមានពាណិជ្ជកម្មនៅក្នុងដែនដីនៃភាគីណាមួយផ្សេងទៀត

(iv) ធ្វើឡើងដោយអ្នកផ្គត់ផ្គង់សេវានៃភាគីមួយ តាមរយៈវត្តមានរូបវន្តបុគ្គលរបស់ភាគីមួយនៅក្នុងដែនដីនៃភាគីណាមួយផ្សេងទៀត

(ឈឈ) **សិទ្ធិធ្វើចរាចរ** មានន័យថា សិទ្ធិក្នុងការផ្តល់សេវាតាមតារាងសន្យា និងមិនតាមតារាងសន្យាសេវាកម្ម ដើម្បីប្រតិបត្តិការ និង/ឬ ដឹកជញ្ជូនអ្នកដំណើរ ទំនិញ និងសំបុត្រ សំរាប់ប្រាក់ឈ្នួល ឬសិទ្ធិជួលផ្លូវហោះហើរទៅ-មក នៅក្នុងឬពីលើដែនដីរបស់ភាគី រួមបញ្ចូលនូវគោលដៅដែលត្រូវផ្តល់សេវា ផ្លូវហោះហើរដែលត្រូវធ្វើប្រតិបត្តិការ ប្រភេទចរាចរដែលត្រូវហោះហើរ សមត្ថភាពដឹកជញ្ជូនដែលត្រូវផ្តល់ជូន តម្លៃដែលត្រូវយក និងលក្ខខ័ណ្ឌនៃការយកតម្លៃនោះ និងលក្ខណៈវិនិច្ឆ័យសំរាប់កំណត់ប្រភេទក្រុមហ៊ុនអាកាសចរ ដោយរួមបញ្ចូលនូវលក្ខណៈវិនិច្ឆ័យស្តីពីចំនួនកម្មសិទ្ធិ និងការគ្រប់គ្រងនៅក្នុងក្រុមហ៊ុនអាកាសចរ។

(ញញ) WTO មានន័យថា អង្គការពាណិជ្ជកម្មពិភពលោក និង

(ដដ) **កិច្ចព្រមព្រៀង** WTO មានន័យថា កិច្ចព្រមព្រៀងម៉ារ៉ាកេសដែលបង្កើតអង្គការពាណិជ្ជកម្មពិភពលោក ដែលបានធ្វើឡើងនៅទីក្រុងម៉ារ៉ាកេសនាថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៩៤ និងកិច្ចព្រមព្រៀងដទៃទៀត ដែលបានចរចានៅក្រោមបរិបទនោះ។

មាត្រា ២
វិសាលភាព

១. កិច្ចព្រមព្រៀងនេះ អនុវត្តចំពោះវិធានការនានាដែលចាត់ឡើងដោយបណ្តាភាគី ដែលជះឥទ្ធិពលដល់ពាណិជ្ជកម្មសេវាកម្ម។

២. កិច្ចព្រមព្រៀងនេះ មិនត្រូវអនុវត្តចំពោះ :

(ក) សេវាកម្មមួយដែលត្រូវបានផ្គត់ផ្គង់នៅក្នុងការអនុវត្តកិច្ចការរបស់អាជ្ញាធររដ្ឋាភិបាលនៅក្នុងដែនដីរបស់ភាគីនីមួយៗ

(ខ) វិធានការនានាដែលជះឥទ្ធិពលដល់សិទ្ធិធ្វើចរាចរផ្លូវអាកាសដែលបានផ្តល់ឱ្យ ឬវិធានការនានាដែលជះឥទ្ធិពលដល់សេវាកម្មទាក់ទិនផ្ទាល់នឹងការអនុវត្តសិទ្ធចរាចរផ្លូវអាកាស ក្រៅពីបណ្តាវិធានការដែលជះឥទ្ធិពលដល់

(i) សេវាជួសជុល និងថែទាំយន្តហោះ

(ii) ការលក់ និងស្វែងរកទីផ្សារសេវាដឹកជញ្ជូនផ្លូវអាកាស និង

(iii) សេវាប្រព័ន្ធផ្ទុកពត៌មានដោយកុំព្យូទ័រ

(គ) នាវាចរណ៍នៅក្នុងសេវាដឹកជញ្ជូនផ្លូវសមុទ្រ និង

(ឃ) វិធានការនានាដែលជះឥទ្ធិពលដល់រូបវន្តបុគ្គលស្វែងរកការងារធ្វើក្នុងទីផ្សារពលកម្មរបស់ភាគីមួយ និងវិធានការនានាទាក់ទិននឹងសញ្ជាតិ សិទ្ធិស្នាក់នៅ ឬប្រកបការងារអចិន្ត្រៃយ៍ ។

៣. មាត្រា១៩ មាត្រា២០ និងមាត្រា២៣ នៃកិច្ចព្រមព្រៀងនេះ នឹងមិនអនុវត្តលើច្បាប់ បទបញ្ជា ឬលក្ខខ័ណ្ឌតម្រូវនានាដែលគ្រប់គ្រងលទ្ធកម្មធ្វើឡើងដោយទីភ្នាក់ងាររដ្ឋាភិបាល ដើម្បីទិញសេវាសំរាប់ប្រើប្រាស់ក្នុងគោលបំណងរដ្ឋាភិបាល និងគ្មានគោលបំណងសំរាប់លក់បន្តសំរាប់គោលដៅពាណិជ្ជកម្ម ឬប្រើប្រាស់នៅក្នុងការផ្គត់ផ្គង់សេវាបំរើគោលបំណងលក់ដូរពាណិជ្ជកម្ម ។

៤. គ្មានអ្វីទាំងអស់នៅក្នុងកិច្ចព្រមព្រៀងនេះ ដែលនឹងរារាំងភាគីមួយមិនឱ្យអនុវត្តវិធានការនានាសំរាប់ធ្វើនិយ័តកម្មការចូលមកនៃរូបវន្តបុគ្គលរបស់បណ្តាភាគីផ្សេងទៀត ឬការស្នាក់នៅបណ្តោះអាសន្នរបស់ពួកគេក្នុងដែនដីរបស់ខ្លួន រួមបញ្ចូលនូវ វិធានការចាំបាច់នានាសំរាប់ការពារបូរណភាព និងធានាបាននូវការឆ្លងកាត់ព្រំដែនប្រកបដោយសណ្តាប់ធ្នាប់នៃរូបវន្តបុគ្គលទាំងនោះ ឱ្យតែវិធានការបែបនេះ មិនអនុវត្តក្នុងលក្ខណៈមួយដែលធ្វើឱ្យមោឃៈ ឬខូចខាតផលប្រយោជន៍នានា[៤] ដែលបានផ្តល់ជូនភាគីដទៃទៀត នៅក្រោមលក្ខខណ្ឌនៃការសន្យាតាមវិស័យ ។

[៤] អង្គហេតុតែមួយគត់ស្តីពីការតំរូវឱ្យមានទិដ្ឋាការសំរាប់រូបវន្តបុគ្គលនៃបណ្តាភាគីណាមួយ និងមិនតំរូវឱ្យមានសំរាប់ភាគីផ្សេងទៀត មិនត្រូវចាត់ទុកថាបានធ្វើឱ្យមោឃៈ ឬខូចខាតផលប្រយោជន៍នានានៅក្រោមការសន្យាតាមវិស័យឡើយ ។

ជំពូក II
ភាតព្វកិច្ច និងវិន័យ

មាត្រា ៣
រដ្ឋាភិបាលតំបន់ និងមូលដ្ឋាន

ក្នុងការបំពេញកាតព្វកិច្ច និងការសន្យារបស់ខ្លួននៅក្រោមកិច្ចព្រមព្រៀងនេះ ភាគីនីមួយៗត្រូវធានានូវការគោរពប្រតិបត្តិពីសំណាក់រដ្ឋាភិបាល និង អាជ្ញាធរតំបន់ និងមូលដ្ឋាននៅក្នុងដែនដីរបស់ខ្លួន ព្រមទាំងការគោរពប្រតិបត្តិពីសំណាក់អង្គការមិនមែនរដ្ឋាភិបាលនានា នៅក្នុងការអនុវត្តកិច្ចការ ដែលត្រូវបានធ្វើប្រតិភូកម្មដោយរដ្ឋាភិបាល ឬអាជ្ញាធរថ្នាក់កណ្តាល តំបន់ ឬមូលដ្ឋាននៅក្នុងដែនដីរបស់ខ្លួន។

មាត្រា ៤
តម្លាភាព

១. ភាគីនីមួយៗត្រូវផ្សព្វផ្សាយភ្លាមៗ និងលើកលែងតែក្នុងស្ថានការណ៍អាសន្នចេញ យ៉ាងយឺតបំផុត ត្រឹមថ្ងៃចូលជាធរមាន នូវរាល់វិធានការពាក់ព័ន្ធទាំងអស់នៃការអនុវត្តន៍ទូទៅដែលពាក់ព័ន្ធ ឬជះឥទ្ធិពលដល់ប្រតិបត្តិការកិច្ចព្រមព្រៀងនេះ។ កិច្ចព្រមព្រៀងអន្តរជាតិដែលពាក់ព័ន្ធ ឬជះឥទ្ធិពលលើពាណិជ្ជកម្មសេវាកម្មដែលភាគីនោះជាភាគីហត្ថលេខី ក៏ត្រូវផ្សព្វផ្សាយផងដែរ។

២. នៅពេលដែលការផ្សព្វផ្សាយដូចមានចែងនៅក្នុងកថាខ័ណ្ឌ១ មិនអាចអនុវត្តបាន ពត៌មានបែបនេះ ត្រូវតែធ្វើយ៉ាងណាឱ្យបានដឹងជាសាធារណៈ។

៣. ភាគីនីមួយៗត្រូវជូនដំណឹងភ្លាមៗ ហើយយ៉ាងហោចណាស់មួយឆ្នាំម្តង ទៅគណៈកម្មការអនុវត្ត នូវរាល់ច្បាប់ បទបញ្ជា ឬសេចក្តីណែនាំរដ្ឋបាលថ្មី ឬការផ្លាស់ប្តូរច្បាប់ បទបញ្ជា ឬសេចក្តីណែនាំរដ្ឋបាល ដែលមានស្រាប់ដែលជះឥទ្ធិពលធ្ងន់ធ្ងរ ដល់ពាណិជ្ជកម្មសេវាកម្ម ហើយដែលគ្របដណ្តប់ក្នុងការសន្យាតាមវិស័យ នៅក្រោមកិច្ចព្រមព្រៀងនេះ។

៤. ភាគីនីមួយៗត្រូវឆ្លើយតបភ្លាមៗទៅនឹងសំណើទាំងអស់ដែលស្នើឡើងដោយភាគីដទៃទៀត នូវរាល់ពត៌មានជាក់ស្តែងនានាស្តីពីវិធានការដែលអនុវត្តជាទូទៅ ឬកិច្ចព្រមព្រៀងអន្តរជាតិនៅក្នុងអត្ថន័យនៃកថាខណ្ឌ១។ ភាគីនីមួយៗ ត្រូវបង្កើតផងដែរ នូវកន្លែងសាកសួរពត៌មានមួយ ឬច្រើន ដើម្បីផ្តល់ពត៌មានជាក់ស្តែងតាមសំណើរបស់ភាគីដទៃទៀតស្តីពីបញ្ហាទាំងអស់នោះ ក៏ដូចកិច្ចការដែលជាកម្មវត្ថុនៃការតំរូវឱ្យធ្វើសេចក្តីជូនដំណឹងក្នុងកថា

ខណ្ឌ៣ ផង។ កន្លែងសាកសួរពត៌មានទាំងនោះត្រូវបង្កើតឡើងក្នុងរង្វង់ពីរឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ។ ភាពទន់ភ្លន់ទាក់ទិននឹងក្របខ័ណ្ឌពេលវេលាសំរាប់បង្កើតកន្លែងសាកសួរពត៌មានបែបនេះ អាចនឹងត្រូវបានព្រមព្រៀងគ្នាសំរាប់ភាគីជាប្រទេសកំពុងអភិវឌ្ឍន៍នីមួយៗ។ កន្លែងសាកសួរពត៌មាន មិនចាំបាច់តែជាកន្លែងតំកល់ច្បាប់ និងបទបញ្ជានានា នោះឡើយ។

៥. ភាគីណាមួយ ក៏អាចជូនដំណឹងដល់គណៈកម្មការអនុវត្ត អំពីវិធានការទាំងឡាយដែលចាត់ឡើងដោយភាគីណាមួយផ្សេងទៀត ដែលភាគីនោះគិតថា ជះឥទ្ធិពលដល់ប្រតិបត្តិការនៃកិច្ចព្រមព្រៀង។

មាត្រា៥

ការបង្ហាញពត៌មានសំខាន់

ពុំមានអ្វីទាំងអស់នៅក្នុងកិច្ចព្រមព្រៀងនេះ ដែលតំរូវឱ្យភាគីណាមួយផ្តល់ពត៌មានសំងាត់នានា ដែលការផ្តល់ពត៌មានទាំងនេះនឹងរារាំងដល់ការអនុវត្តច្បាប់ ឬផ្ទុយនឹងផលប្រយោជន៍សាធារណៈ ឬនឹងធ្វើឱ្យខូចខាតផលប្រយោជន៍ពាណិជ្ជកម្មស្របច្បាប់របស់សហគ្រាសសាធារណៈ ឬឯកជន ណាមួយឡើយ។

មាត្រា ៦

បទបញ្ជាក្នុងស្រុក

១. នៅក្នុងវិស័យនានាដែលការសន្យាតាមវិស័យត្រូវបានធ្វើឡើង ភាគីនីមួយៗ ត្រូវធានាថា វិធានការទាំងអស់នៃការអនុវត្តន៍ទូទៅដែលជះឥទ្ធិពលដល់ពាណិជ្ជកម្មសេវាកម្ម ត្រូវបានចាត់ចែងក្នុងលក្ខណៈសមស្រប សត្យានុម័ត និងមិនលំអៀង ។

២. (ក) ភាគីនីមួយៗត្រូវរក្សា ឬបង្កើតឱ្យបានឆាប់តាមដែលអាចធ្វើបាន នូវនីតិវិធី ឬវេទិការតុលាការមជ្ឈត្តការ ឬរដ្ឋបាល តាមសំណើរបស់អ្នកផ្គត់ផ្គង់សេវាដែលរងការប៉ះពាល់ ដើម្បីឱ្យមានការត្រួតពិនិត្យភ្លាមៗលើបណ្តាសេចក្តីសម្រេចរដ្ឋបាលដែលជះឥទ្ធិពលដល់ពាណិជ្ជកម្មសេវាកម្ម។ នៅពេលដែលនីតិវិធីទាំងនោះ មិនមានឯករាជ្យភាពពីភ្នាក់ងារសមត្ថកិច្ច ដែលចេញសេចក្តីសម្រេចរដ្ឋបាលដែលពាក់ព័ន្ធ ភាគីនោះត្រូវធានាថា នីតិវិធីទាំងនោះនឹងត្រូវពិនិត្យឡើងវិញដោយសត្យានុម័ត និងមិនលំអៀង។

(ខ) បទប្បញ្ញត្តិទាំងឡាយនៃកថាខណ្ឌរង (ក) នឹងមិនត្រូវបកស្រាយ ដើម្បីតម្រូវឱ្យភាគីណាមួយបង្កើតវេទិកា ឬនីតិវិធីទាំងនោះ ដែលមិនស្របនឹងរចនាសម្ព័ន្ធរដ្ឋធម្មនុញ្ញ ឬសារជាតិនៃប្រព័ន្ធច្បាប់របស់ខ្លួនឡើយ ។

៣. នៅទីណាដែលតំរូវឱ្យមានការស្នើសុំការអនុញ្ញាតដើម្បីផ្គត់ផ្គង់សេវា តាមការសន្យាតាមវិស័យ អាជ្ញាធរមានសមត្ថកិច្ចទាំងឡាយនៃភាគីមួយ ក្នុងរយៈពេលសមស្រប បន្ទាប់ពីពាក្យសុំត្រូវបានចាត់ទុកថាគ្រប់ជ្រុងជ្រោយ តាមការតម្រូវរបស់ច្បាប់ និងបទបញ្ញាក្នុងស្រុក ត្រូវជូនដំណឹងដល់អ្នកដាក់ពាក្យសុំអំពីសេចក្តីសម្រេចពាក់ព័ន្ធនឹងពាក្យសុំនោះ។ តាមសំណើរបស់អ្នកដាក់ពាក្យសុំ អាជ្ញាធរមានសមត្ថកិច្ចទាំងឡាយនៃភាគីនោះ ដោយមិនបង្អែបង្អង់ដោយគ្មានហេតុផល ត្រូវផ្តល់ពត៌មាននានាទាក់ទិននឹងស្ថានភាពនៃពាក្យសុំ នោះ។

៤. ដោយមានបំណងចង់ធានាថា វិធានការនានាទាក់ទិននឹងលក្ខខ័ណ្ឌតម្រូវ និងនីតិវិធីគុណវុឌ្ឍិ បទដ្ឋានបច្ចេកទេស និងលក្ខខណ្ឌតំរូវអាជ្ញាប័ណ្ណ នឹងមិនបង្កឧបសគ្គមិនចាំបាច់ចំពោះពាណិជ្ជកម្មសេវាកម្ម គណៈកម្មការអនុវត្តន៍ តាមរយៈអង្គភាពសមស្របមួយចំនួនដែលខ្លួនអាចបង្កើតបាន ត្រូវបង្កើតវិន័យចាំបាច់មួយចំនួន។ វិន័យទាំងនោះត្រូវមានទិសដៅធានាថា ក្នុងចំណោមលក្ខខ័ណ្ឌតម្រូវទាំងនោះ:

(ក) ត្រូវផ្អែកលើលក្ខណៈវិនិច្ឆ័យនៃកម្មវត្ថុ និងតម្លាភាព ដូចជា សមត្ថភាព និងលទ្ធភាពក្នុងការផ្គត់ផ្គង់សេវា

(ខ) មិនដាក់បន្ទុកថែមទៀតលើសពីការចាំបាច់ ដើម្បីធានាគុណភាពសេវា

(គ) នៅក្នុងករណីនីតិវិធីផ្តល់អាជ្ញាប័ណ្ណ លក្ខខណ្ឌតម្រូវនោះផ្ទាល់មិនត្រូវក្លាយជាការរឹតត្បិតលើការផ្គត់ផ្គង់សេវាឡើយ។

៥. (ក) នៅក្នុងវិស័យនានាដែលភាគីមួយបានធ្វើការសន្យាតាមវិស័យ ដោយរង់ចាំការចូលជាធរមាននៃវិន័យនានាដែលបានបង្កើតឡើងក្នុងវិស័យទាំងនោះ អនុលោមតាមកថាខណ្ឌ៤ ភាគីនោះមិនត្រូវប្រើប្រាស់លក្ខខ័ណ្ឌតម្រូវអាជ្ញាប័ណ្ណ និងគុណវុឌ្ឍិ និងបទដ្ឋានបច្ចេកទេសនានាដែលធ្វើឱ្យមោឃៈ ឬប៉ះពាល់ដល់ការសន្យាទាំងនោះ ក្នុងលក្ខណៈមួយដែល:

(i) មិនស្របជាមួយលក្ខណៈវិនិច្ឆ័យដែលមានចែងក្នុងវាក្យខ័ណ្ឌរង៤ (ក),(ខ) ឬ (គ) និង

(ii) មិនអាចត្រូវបានរំពឹងទុកដោយសមហេតុផលពីសំណាក់ភាគីនោះនៅខណៈពេលដែលការសន្យាតាមវិស័យទាំងនោះត្រូវបានធ្វើឡើង។

(ខ) ក្នុងការកំណត់ថាតើ ភាគីមួយអនុវត្តស្របតាមកាតព្វកិច្ចដែលមានចែងក្នុងកថាខណ្ឌ៥(ក) ឬទេ ត្រូវពិចារណាដល់បទដ្ឋានអន្តរជាតិរបស់អង្គការអន្តរជាតិពាក់ព័ន្ធនានា[៥] ដែលប្រើប្រាស់ដោយភាគីនោះ។

៦. នៅក្នុងវិស័យដែលការសន្យាតាមវិស័យពាក់ព័ន្ធនឹងសេវាវិជ្ជាជីវៈត្រូវបានធ្វើឡើង ភាគីនីមួយៗ ត្រូវផ្តល់នីតិវិធីគ្រប់គ្រាន់ដើម្បីផ្ទៀងផ្ទាត់សមត្ថភាពវិជ្ជាជីវៈនៃភាគីណាមួយផ្សេងទៀត។

មាត្រា ៧
ការទទួលស្គាល់

១. សំរាប់គោលបំណងនៃការអនុវត្តន៍ទាំងស្រុង ឬដោយផ្នែកនូវបទដ្ឋាន ឬលក្ខណៈវិនិច្ឆ័យសំរាប់ការអនុញ្ញាត ផ្តល់អាជ្ញាប័ណ្ណ ឬចេញវិញ្ញាប័នបត្រចំពោះអ្នកផ្គត់ផ្គង់សេវា ភាគីនីមួយៗអាចទទួលស្គាល់ការសិក្សាអប់រំ ឬបទពិសោធន៍ដែលទទួលបាន ការបំពេញបានតាមលក្ខខ័ណ្ឌតម្រូវ ឬអាជ្ញាប័ណ្ណ ឬវិញ្ញាបនបត្រ ដែលបានផ្តល់ជូនក្នុងប្រទេសរបស់ភាគីមួយទៀត។ ការទទួលស្គាល់បែបនេះ អាចសំម្រេចបានតាមរយៈសុខដុមកម្មវូបនីយកម្ម ឬអាចផ្អែកលើកិច្ចព្រមព្រៀងឬ ការរៀបចំរវាងបណ្តាភាគី ឬអង្គភាពមានសមត្ថកិច្ចពាក់ព័ន្ធ ឬត្រូវបានផ្តល់ជាស្វ័យតភាព។

២. ភាគីដែលជាភាគីមួយនៃប្រភេទកិច្ចព្រមព្រៀង ឬការរៀបចំដែលមានចែងក្នុងកថាខណ្ឌ១ ទោះជាកំពុងមានអត្ថិភាព ឬនឹងកើតមាននាពេលអនាគតក្តី ត្រូវផ្តល់ឱកាសគ្រប់គ្រាន់ដល់ភាគីពាក់ព័ន្ធដទៃទៀត ដើម្បីអាចចូលរួមចរចាលើកិច្ចព្រមព្រៀង ឬការរៀបចំបែបនោះ ឬកិច្ចព្រមព្រៀងឬការរៀបចំស្រដៀងគ្នានេះ។ នៅពេលណាដែលភាគីមួយផ្តល់ ការទទួលស្គាល់ដោយស្វ័យតភាព ភាគីនោះ ត្រូវផ្តល់ឱកាសគ្រប់គ្រាន់ដើម្បីឱ្យភាគីផ្សេងទៀតបង្ហាញថា ការសិក្សាអប់រំ បទពិសោធន៍ អាជ្ញាប័ណ្ណ ឬវិញ្ញាបនបត្រ ដែលទទួលបាន ឬដែលបំពេញបានតាមលក្ខខណ្ឌតំរូវនៅក្នុងដែនដីរបស់ភាគីដទៃទៀត ក៏នឹងត្រូវបានទទួលស្គាល់ផងដែរ។

[៥] ពាក្យថា "អង្គការអន្តរជាតិពាក់ព័ន្ធ" សំដៅលើអង្គការអន្តរជាតិដែលបើកទូលាយសមាជិកភាពរបស់ខ្លួនដល់អង្គភាពពាក់ព័ន្ធនានាយ៉ាងហោចណាស់នៃសមាជិកអង្គការពាណិជ្ជកម្មពិភពលោកទាំងអស់ដែរ។

៣. ភាគីមួយមិនត្រូវផ្តល់ការទទួលស្គាល់ក្នុងលក្ខណៈមួយដែលនឹងបង្កើតឱ្យមានការរើសអើងរវាងប្រទេសនានា នៅក្នុងការអនុវត្តនីបទដ្ឋាន ឬលក្ខណៈវិនិច្ឆ័យរបស់ខ្លួនសម្រាប់ការផ្តល់ការអនុញ្ញាត អាជ្ញាប័ណ្ណ ឬ វិញ្ញាបនប័ត្រ ដល់អ្នកផ្គត់ផ្គង់សេវា ឬការរឹតត្បិតជាលក្ខណៈបិទបាំងលើពាណិជ្ជកម្មសេវាកម្មឡើយ ។

៤. ភាគីនីមួយៗ ត្រូវប្រឹងប្រែងៈ

(ក) ក្នុងអំឡុងពេល១២ខែ គិតចាប់ពីកាលបរិច្ឆេទដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន ត្រូវជូនដំណឹងទៅគណៈកម្មការអនុវត្តអំពីវិធានការទទួលស្គាល់គ្នាដែលមានស្រាប់ និងបញ្ជាក់ថាតើវិធានការទាំងនោះ ត្រូវបានចាត់ឡើងដោយផ្អែកតាមប្រភេទកិច្ចព្រមព្រៀង ឬការព្រមព្រៀងដែលមានចែងក្នុងកថាខណ្ឌ១ ឬទេ

(ខ) ត្រូវជូនដំណឹងភ្លាមៗទៅគណៈកម្មការអនុវត្តឱ្យបានមុនតាមដែលអាចធ្វើទៅបាននូវរាល់ការចាប់ផ្តើមនៃការចរចាលើកិច្ចព្រមព្រៀង ឬការរៀបចំដូចប្រភេទដែលមានចែងនៅក្នុងកថាខណ្ឌ១ ដើម្បីផ្តល់ឱកាសគ្រប់គ្រាន់ដល់ភាគីផ្សេងទៀត ដើម្បីបង្ហាញពីចំណាប់អារម្មណ៍របស់ខ្លួនក្នុងការចូលរួមក្នុងការចរចានោះ មុនពេលដែលការចរចាទាំងនោះឈានចូលដល់ដំណាក់កាលស៊ីជម្រៅ

(គ) ត្រូវជូនដំណឹងភ្លាមៗដល់គណៈកម្មការអនុវត្ត នៅពេលអនុម័តវិធានការទទួលស្គាល់ ឬកែប្រែជាដុំកំភួននូវវិធានការដែលមានពីមុនមក និងបញ្ជាក់ថា វិធានការទាំងនោះ ផ្អែកតាម ឬមិនផ្អែកតាមប្រភេទកិច្ចព្រមព្រៀង ឬការរៀបចំដែលមានចែងក្នុងកថាខណ្ឌ ១ ។

៥. នៅពេលណាមួយសមស្រប ការទទួលស្គាល់ត្រូវផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានព្រមព្រៀងគ្នាជាពហុភាគី។ ក្នុងករណីសមស្រប បណ្តាភាគីត្រូវធ្វើសហប្រតិបត្តិការជាមួយអង្គការអន្តររដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធ សំដៅបង្កើត និងអនុម័តបទដ្ឋានអន្តរជាតិ និងលក្ខណៈវិនិច្ឆ័យរួមសំរាប់ការទទួលស្គាល់ និងបទដ្ឋានអន្តរជាតិរួម សំរាប់ការអនុវត្តសេវាកម្មពាណិជ្ជកម្ម និង វិជ្ជាជីវៈពាក់ព័ន្ធ ។

មាត្រា ៨

ភាពផ្តាច់មុខ និងអ្នកផ្គត់ផ្គង់សេវាផ្តាច់មុខ

១. ភាគីនីមួយៗត្រូវធានាថាអ្នកផ្គត់ផ្គង់សេវាផ្តាច់មុខណាមួយនៅក្នុងដែនដីរបស់ខ្លួន នៅក្នុងការផ្គត់ផ្គង់សេវាផ្តាច់មុខក្នុងទីផ្សារពាក់ព័ន្ធនានា នឹងមិនប្រព្រឹត្តក្នុងលក្ខណៈមួយដែលមិនស្របតាមកាតព្វកិច្ចរបស់ភាគីនោះ ដោយអនុលោមតាមមាត្រា១៩ និងមាត្រា២០ ។

២. នៅពេលដែលអ្នកផ្គត់ផ្គង់ផ្តាច់មុខរបស់ភាគីមួយ ប្រកួតប្រជែងដោយផ្ទាល់ ឬតាមរយៈក្រុមហ៊ុនសម្ព័ន្ធភាព ក្នុងការផ្គត់ផ្គង់សេវាដែលស្ថិតក្រៅវិសាលភាពនៃសិទ្ធិផ្តាច់មុខរបស់ខ្លួន និងដែលជាកម្មវត្ថុនៃការសន្យាតាមវិស័យរបស់ភាគីនោះ ភាគីនោះត្រូវធានាថា អ្នកផ្គត់ផ្គង់នេះ នឹងមិនប្រើប្រាស់បំពាននូវតួនាទីផ្តាច់មុខរបស់ខ្លួនក្នុងការផ្គត់ផ្គង់នៅក្នុងដែនដីរបស់ភាគីក្នុងលក្ខណៈមួយដែលមិនសមស្របនឹងការសន្យាទាំងនោះ ។

៣. ប្រសិនបើភាគីណាមួយមានមូលហេតុដែលគួរឱ្យជឿថា អ្នកផ្គត់ផ្គង់សេវាផ្តាច់មុខនៃភាគីមួយផ្សេងទៀត កំពុងតែប្រព្រឹត្តិមិនស្របនឹងកថាខណ្ឌ១ ឬ២ ភាគីនោះ អាចស្នើភាគីដែលបង្កើត រក្សាទុក ឬអនុញ្ញាតឱ្យអ្នកផ្គត់ផ្គង់សេវានោះ ផ្តល់ពត៌មានជាក់លាក់អំពីប្រតិបត្តិការពាក់ព័ន្ធរបស់ខ្លួនបាន ។

៤. បទបញ្ញត្តិនានានៃមាត្រានេះ ក៏ត្រូវអនុវត្តផងដែរចំពោះករណីដែលអ្នកផ្គត់ផ្គង់សេវាផ្តាច់មុខទាំងឡាយដែលភាគីមួយ ជាផ្លូវការ ឬជាឥទ្ធិពលៈ

(ក) អនុញ្ញាត ឬបង្កើតឱ្យមានអ្នកផ្គត់ផ្គង់សេវាមួយក្រុមតូច និង

(ខ) រារាំងស្ទើរតែទាំងស្រុងមិនឱ្យមានការប្រកួតប្រជែងក្នុងចំណោមអ្នកផ្គត់ផ្គង់ទាំងនោះនៅក្នុងដែនដីរបស់ខ្លួន ។

៥. ប្រសិនបើ បន្ទាប់ពីថ្ងៃចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ភាគីមួយផ្តល់សិទ្ធិផ្តាច់មុខសំរាប់ការផ្គត់ផ្គង់សេវាដែលស្ថិតក្នុងការសន្យាតាមវិស័យរបស់ខ្លួន ភាគីនោះត្រូវជូនដំណឹងទៅគណៈកម្មការអនុវត្តនឹមិនឱ្យលើសបីខែ មុនពេលចាប់ផ្តើមផ្តល់សិទ្ធិផ្តាច់មុខនោះ ហើយត្រូវយកបទបញ្ញត្តិនានានៃកថាខណ្ឌ១(ខ) (ក្រៅពីការរឹតត្បិតសំរាប់រយៈពេលបីឆ្នាំ) ២ ៣ ៤ និង៥ នៃមាត្រា២៥ មកអនុវត្ត ។

មាត្រា ៩

ការអនុវត្តធុរកិច្ច

១. បណ្តាភាគីទទួលស្គាល់ថា ការអនុវត្តធុរកិច្ចមួយចំនួនរបស់អ្នកផ្គត់ផ្គង់សេវា ក្រៅពីការអនុវត្តដែលមានចែងក្នុងមាត្រា៨ អាចបន្ទុចបង្អាក់ការប្រកួតប្រជែង និងដោយសារហេតុផលនេះហើយ ធ្វើឱ្យរឹតត្បិតពាណិជ្ជកម្មសេវាកម្ម ។

២. ភាគីនីមួយៗ តាមសំណើរបស់ភាគីណាមួយផ្សេងទៀត ("ភាគីស្នើសុំ") ត្រូវចូលរួមពិគ្រោះយោបល់ក្នុងគោលបំណងដើម្បីលុបបំបាត់ការអនុវត្តនានាដែលមានចែងក្នុងកថាខ័ណ្ឌ១។ ភាគីដែលត្រូវបានស្នើសុំនោះត្រូវពិចារណាឱ្យបានពេញលេញ និងប្រកបដោយសមានចិត្តចំពោះសំណើបែបនេះ និងត្រូវធ្វើសហប្រតិបត្តិការតាមរយៈការផ្តល់ពត៌មានមិនសំងាត់ដែលអាចរកបានជាសាធារណៈទាក់ទិននឹងបញ្ហាដែលជាកម្មវត្ថុ នោះ។ ភាគីដែលត្រូវបានស្នើសុំក៏ត្រូវផ្តល់ផងដែរនូវពត៌មានដែលអាចរកបានដទៃទៀតតាមសំណើរបស់ភាគីស្នើសុំ ផ្អែកតាមច្បាប់ក្នុងស្រុករបស់ភាគីនោះ និងអាស្រ័យលើការព្រមព្រៀងគ្នាស្តីពីកិច្ចការពារការសំងាត់របស់ភាគីស្នើសុំ។

មាត្រា ១០
ការការពារ

១. បណ្តាភាគីកត់សំគាល់អំពីកិច្ចចរចាពហុភាគី អនុលោមតាមមាត្រា X នៃកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្មស្តីពីបញ្ហាវិធានការការពារក្នុងសភាពអាសន្ន ផ្អែកលើគោលការណ៍មិនរើសអើង។ នៅពេលបញ្ចប់កិច្ចចរចាពហុភាគីទាំងនោះ បណ្តាភាគីត្រូវធ្វើការពិនិត្យឡើងវិញសំដៅពិភាក្សាអំពីការធ្វើវិសោធនកម្មសមស្របចំពោះកិច្ចព្រមព្រៀងនេះ ដើម្បីបញ្ចូលលទ្ធផលនៃកិច្ចចរចាពហុភាគីនោះ។

២. នៅក្នុងករណីដែលការអនុវត្តកិច្ចព្រមព្រៀងនេះ បណ្តាលឱ្យកើតមានផលប៉ះពាល់ធ្ងន់ធ្ងរទៅលើវិស័យសេវាកម្មរបស់ភាគីមួយ នៅមុនការបញ្ចប់កិច្ចចរចាពហុភាគីដែលយោងក្នុងកថាខណ្ឌ១ ភាគីដែលរងការប៉ះពាល់អាចស្នើសុំឱ្យមានកិច្ចពិគ្រោះយោបល់ជាមួយភាគីដទៃទៀតដើម្បីពិភាក្សាអំពីការចាត់វិធានការលើវិស័យសេវាកម្មដែលរងការប៉ះពាល់នោះ។ វិធានការណាមួយក៏ដោយ ដែលចាត់ឡើងអនុលោមតាមកថាខណ្ឌនេះ ត្រូវតែមានការព្រមព្រៀងគ្នាទៅវិញទៅមកដោយភាគីពាក់ព័ន្ធ។ បណ្តាភាគីពាក់ព័ន្ធត្រូវយកមកពិចារណានូវកាលៈទេសៈនៃករណីជាក់ស្តែងនីមួយៗនិងផ្តល់នូវការពិចារណាប្រកបដោយសមានចិត្តចំពោះភាគីដែលស្នើសុំឱ្យចាត់វិធានការ។

មាត្រា ១១
ការទូទាត់ និងការផ្ទេរ

១. លើកលែងតែស្ថិតក្រោមកាលៈទេសៈដែលបានប្រមើលទុកនៅក្នុងមាត្រា១២ ចេញ ភាគីមួយមិនត្រូវដាក់ការរឹតត្បិតចំពោះការផ្ទេរ និងទូទាត់អន្តរជាតិ សម្រាប់ប្រតិបត្តិការចរន្តទាំងឡាយទាក់ទិននឹងការសន្យាតាមវិស័យរបស់ខ្លួន។

២. គ្មានអ្វីទាំងអស់នៅក្នុងកិច្ចព្រមព្រៀងនេះ ដែលនឹងត្រូវប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីណាមួយ ដែលជាសមាជិកមូលនិធិរូបិយវត្ថុអន្តរជាតិអនុលោមតាមកិច្ចព្រមព្រៀងមូលនិធិរូបិយវត្ថុអន្តរជាតិ រួមបញ្ចូលទាំងការប្រើប្រាស់សកម្មភាពដោះដូរដោយអនុលោមតាមកិច្ចព្រមព្រៀងមូលនិធិរូបិយវត្ថុអន្តរជាតិ ឱ្យតែភាគីនោះមិនដាក់ការរឹតត្បិតលើប្រតិបត្តិការមូលធនណាមួយផ្ទុយពីការសន្យាតាមវិស័យរបស់ខ្លួនពាក់ព័ន្ធនឹងប្រតិបត្តិការនោះ លើកលែងតែការរឹតត្បិតក្រោមមាត្រា១២ ឬផ្អែកតាមសំណើរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ។

មាត្រា ១២
ការរឹតត្បិតដើម្បីការពារជញ្ជីងទូទាត់

១. នៅពេលណាដែលភាគីមួយមានស្ថានជញ្ជីងទូទាត់ធ្ងន់ធ្ងរ និងជួបការលំបាកខាងហិរញ្ញវត្ថុក្រៅប្រទេស ឬមានការគំរាមកំហែងពីស្ថានការណ៍បែបនោះ ភាគីនោះអាចអនុម័ត ឬរក្សាការរឹតត្បិតចំពោះពាណិជ្ជកម្មសេវាកម្ម ដោយអនុលោមតាមមាត្រា XII របស់កិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម ។

២. រាល់ការរឹតត្បិត ដែលបានអនុម័ត ឬរក្សាទុកនៅក្នុងកថាខណ្ឌ១ ឬការកែប្រែណាមួយចំពោះការរឹតត្បិតទាំងនោះ ត្រូវជូនដំណឹងជាបន្ទាន់ទៅគណៈកម្មការអនុវត្ត ។

មាត្រា ១៣
ការលើកលែងទូទៅ

យោងតាមលក្ខខណ្ឌតម្រូវដែលវិធានការបែបនេះ មិនត្រូវបានអនុវត្តក្នុងលក្ខណៈមួយដែលនឹងនាំឱ្យមានការរើសអើងដោយមិនស្មើភាព ឬគ្មានយុត្តិកម្មរវាងបណ្តាភាគីដែលមានលក្ខខណ្ឌដូចគ្នា ឬរឹតត្បិតពាណិជ្ជកម្មសេវាកម្មដោយបិទបាំង គ្មានអ្វីទាំងអស់នៅក្នុងកិច្ចព្រមព្រៀងនេះដែលនឹងត្រូវបកស្រាយដើម្បីធ្វើការរារាំងដល់ការអនុម័ត ឬការអនុវត្តដោយភាគីណាមួយនូវបណ្តាវិធានការដែលៈ

ក. ចាំបាច់សម្រាប់ការពារសីលធម៌សាធារណៈ ឬដើម្បីថែរក្សាសណ្តាប់ធ្នាប់សាធារណៈ[៦]

ខ. ចាំបាច់សំរាប់ការពារជីវិត ឬ សុខភាពមនុស្ស សត្វ ឬរុក្ខជាតិ

គ. ចាំបាច់សំរាប់ធានាឱ្យមានភាពស្របតាមច្បាប់ ឬបទបញ្ជាទាំងឡាយដែលមិនផ្ទុយពីបទបញ្ញត្តិនានានៃកិច្ចព្រមព្រៀងនេះ រួមបញ្ចូលនូវអ្វីៗដែលពាក់ព័ន្ធនឹងៈ

---

[៦] ការលើកលែងសំរាប់កិច្ចការពារសណ្តាប់ធ្នាប់សាធារណៈ អាចធ្វើឡើងបានតែនៅពេលណាមានការគំរាមកំហែងពិតប្រាកដ និងធ្ងន់ធ្ងរទៅលើផលប្រយោជន៍ជាអាយុជីវិតណាមួយរបស់សង្គមប៉ុណ្ណោះ ។

(i) ការទប់ស្កាត់ការអនុវត្តបែបឆបោក និងទុច្ចរិត ឬចាត់វិធានការទល់នឹងការខកខានមិនបានបំពេញតាមកិច្ចសន្យាសេវាកម្ម។

(ii) ការការពារជីវិតឯកជននៃបុគ្គលម្នាក់ៗទាក់ទិននឹងការស្វែងរក និងផ្សព្វផ្សាយទិន្នន័យផ្ទាល់ខ្លួន និងការការពារសំងាត់នៃប្រវត្តិរូប និងគណនីផ្ទាល់ខ្លួន។

(iii) សុវត្ថិភាព។

ឃ. មិនអនុលោមតាមមាត្រា២០ លើកលែងតែប្រព្រឹត្តិកម្មខុសគ្នាធ្វើឡើងសំដៅធានាបាននូវការកំណត់ ឬប្រមូលពន្ធផ្ទាល់ប្រកបដោយសមធម៌ ឬមានប្រសិទ្ធភាព[៧] ពីសេវាកម្ម និងអ្នកផ្គត់ផ្គង់សេវារបស់ភាគីដទៃទៀត។

ង. ដោយមានប្រព្រឹត្តិកម្មខុសគ្នា លើកលែងតែមានកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធទ្វេដងឬដោយសារបទប្បញ្ញត្តិមួយចំនួនស្តីពីការចៀសវាងការយកពន្ធទ្វេដងនៅក្នុងកិច្ចព្រមព្រៀង ឬការរៀបចំអន្តរជាតិផ្សេងៗទៀត ដែលភាគីនោះត្រូវជាប់កាតព្វកិច្ច។

---

[៧] វិធានការនានាដែលមានទិសដៅធានាសមធម៌ ឬប្រសិទ្ធភាពក្នុងការកំណត់ ឬប្រមូលពន្ធផ្ទាល់ រួមបញ្ចូលនូវវិធានការនានាដែលអនុវត្តដោយភាគីមួយនៅក្រោមប្រព័ន្ធពន្ធដាររបស់ខ្លួន សំដៅ:

i. អនុវត្តចំពោះអ្នកផ្គត់ផ្គង់សេវាមិនមែនពលរដ្ឋក្នុងស្រុក ដោយទទួលស្គាល់ថា កាតព្វកិច្ចពន្ធសំរាប់បុគ្គលមិនមែនពលរដ្ឋក្នុងស្រុក គឺត្រូវកំណត់ផ្អែកតាមប្រភព ឬទីកន្លែងដែលទំនិញជាប់ពន្ធនោះស្ថិតនៅក្នុងទឹកដីនៃភាគី ឬ

ii. អនុវត្តចំពោះបុគ្គលមិនមែនពលរដ្ឋក្នុងស្រុក ដើម្បីធានាអនុវត្តបាននូវការកំណត់ ឬប្រមូលពន្ធនៅក្នុងដែនដីរបស់ភាគី ឬ

iii. អនុវត្តចំពោះបុគ្គលមិនមែនពលរដ្ឋក្នុងស្រុកដើម្បីទប់ស្កាត់ការគេចវេះ ឬចៀសវាងមិនបង់ពន្ធ រួមបញ្ចូលនូវវិធានការសង្កតភាពផង ឬ

iv. អនុវត្តចំពោះអ្នកប្រើប្រាស់សេវាដែលត្រូវបានផ្គត់ផ្គង់នៅក្នុង ឬមកពីដែនដីនៃភាគីមួយផ្សេងទៀតដើម្បីធានាអនុវត្តបាននូវការកំណត់ ឬ ប្រមូលពន្ធពីអ្នកប្រើប្រាស់ទាំងនោះមកពីប្រភពនានានៅក្នុងដែនដីនៃភាគី ឬ

v. ញែកឱ្យដាច់ពីគ្នារវាងអ្នកផ្គត់ផ្គង់សេវាដែលជាកម្មវត្ថុនៃការយកពន្ធលើទំនិញដែលត្រូវជាប់ពន្ធនៅទូទាំងសកលលោក និងអ្នកផ្គត់ផ្គង់សេវាដទៃទៀត ដោយទទួលស្គាល់នូវសារជាតិខុសគ្នានៃមូលដ្ឋានពន្ធរវាងប្រភេទទាំងនោះ ឬ

vi. កំណត់, ឬបែងចែកប្រាក់ចំណូល, ប្រាក់ចំណេញសុទ្ធ, ចំណេញ, កំហាត, ដកប្រាក់ ឬឥណទានរបស់ពលរដ្ឋ ឬសាខាក្នុងស្រុក ឬរវាងបុគ្គល ឬសាខាពាក់ព័ន្ធនៃបុគ្គលដដែលនោះ ដើម្បីការពារមូលដ្ឋានពន្ធរបស់ភាគី។

វាក្យស័ព្ទ ឬសញ្ញាណស្តីពីពន្ធនៅក្នុងវាក្យខ័ណ្ឌ(ឃ)នៃមាត្រា១៣ (ការលើកលែងទូទៅ) និងនៅក្នុងកំណត់សំគាល់នេះ គឺត្រូវកំណត់ផ្អែកតាមបណ្តានិយមន័យ និងសញ្ញាណស្តីពីពន្ធ ឬបណ្តានិយមន័យ និងសញ្ញាណសមមូល ឬប្រហាក់ប្រហែល ដែលមាននៅក្នុងច្បាប់ក្នុងស្រុករបស់ភាគីដែលចាត់វិធានការ។

មាត្រា១៤
ការលើកលែងដោយមូលហេតុសន្តិសុខ

១. គ្មានអ្វីទាំងអស់នៅក្នុងកិច្ចព្រមព្រៀងនេះ នឹងត្រូវបកស្រាយដើម្បីៈ

ក. តម្រូវឱ្យភាគីណាមួយផ្តល់ពត៌មានទាំងឡាយ ដែលការទម្លាយពត៌មាននោះត្រូវបានគិតថាផ្ទុយនឹងផលប្រយោជន៍សន្តិសុខជាសារវន្តរបស់ភាគីនោះ ឬ

ខ. រារាំងភាគីណាមួយមិនឱ្យចាត់វិធានការនានាដែលគិតថាចាំបាច់សំរាប់ការពារផលប្រយោជន៍សន្តិសុខរបស់ខ្លួន ដែលរួមមាន ប៉ុន្តែមិនកំហិតត្រឹមតែៈ

i. សកម្មភាពទាក់ទិននឹងសម្ភារៈដែលអាចបំបែក ឬរំលាយបញ្ចូលគ្នាបាន ឬ សម្ភារៈនានាដែលកើតចេញពីសារធាតុទាំងនេះ

ii. សកម្មភាពដែលធ្វើឡើងការផ្តល់សេវាដែលធ្វើឡើងដោយផ្ទាល់ឬដោយប្រយោលសម្រាប់គោលបំណងផ្គត់ផ្គង់ដល់មូលដ្ឋានយោធា

iii. សកម្មភាពដែលធ្វើឡើងសំដៅការពារហេដ្ឋារចនាសម្ព័ន្ធសាធារណៈជាអាយុជីវិត រួមបញ្ចូល ទាំងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ទឹក និងថាមពល ពីការប៉ុនប៉ងធ្វើឱ្យខូចខាត ឬបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធទាំងនោះ

iv. សកម្មភាពដែលធ្វើឡើងក្នុងពេលមានសង្គ្រាម ឬសភាពអាសន្នក្នុងទំនាក់ទំនងស្រុក ឬអន្តរជាតិ ឬ

គ. រារាំងសមាជិកនានាមិនឱ្យចាត់វិធានការណាមួយ ស្របតាមកាតព្វកិច្ចរបស់ខ្លួនតាមធម្មនុញ្ញអង្គការសហប្រជាជាតិ សំរាប់កិច្ចថែរក្សាសន្តិភាព និងសន្តិសុខអន្តរជាតិ ។

២. គណៈកម្មាការអនុវត្ត ត្រូវបានជូនដំណឹងឱ្យបានពេញលេញបំផុតតាមដែលអាចធ្វើទៅបាន អំពីវិធានការដែលចាត់ឡើងតាមកថាខណ្ឌ១ (ខ)និង(គ) ព្រមទាំងការបញ្ចប់វិធានការទាំងនោះផង

មាត្រា ១៥
ឧបត្ថម្ភធន

១. លើកលែងតែមានចែងនៅក្នុងមាត្រានេះ កិច្ចព្រមព្រៀងនេះមិនត្រូវអនុវត្តចំពោះឧបត្ថម្ភធន ឬ ជំនួយផ្សេងៗផ្តល់ដោយភាគីមួយ ឬចំពោះលក្ខខ័ណ្ឌណាមួយដែលភ្ជាប់ជាមួយនឹងការទទួល ឬការបន្តទទួលនូវឧបត្ថម្ភ

ធន ឬជំនួយបែបនេះឡើយ ទោះបីជាឧបត្ថម្ភធន ឬជំនួយទាំងនោះត្រូវបានផ្តល់ផ្ទាល់មុខ ឬមិនផ្ទាល់មុខចំពោះសេវាកម្មក្នុងស្រុក អ្នកប្រើប្រាស់សេវា ឬអ្នកផ្គត់ផ្គង់សេវាក៏ដោយ។ ប្រសិនបើ ឧបត្ថម្ភធន ឬជំនួយទាំងនោះជះឥទ្ធិពលធំធេងដល់ពាណិជ្ជកម្មសេវាកម្មដែលបានសន្យានៅក្នុងកិច្ចព្រមព្រៀងនេះ ភាគីនានាអាចស្នើសុំពិគ្រោះយោបល់ ដើម្បីរកដំណោះស្រាយប្រកបដោយមិត្តភាពចំពោះបញ្ហានេះ។

២. អនុលោមតាមកិច្ចព្រមព្រៀងនេះ បណ្តាភាគីត្រូវ:

ក. ផ្អែកតាមការស្នើសុំ ផ្តល់ពត៌មានស្តីពីឧបត្ថម្ភធនទាក់ទិននឹងពាណិជ្ជកម្មសេវាកម្ម ដែលបានសន្យានៅក្នុងកិច្ចព្រមព្រៀងនេះ ជូនដល់ភាគីស្នើសុំ និង

ខ. ពិនិត្យឡើងវិញនូវប្រព្រឹត្តិកម្មនៃឧបត្ថម្ភធន នៅពេលណាវិន័យពាក់ព័ន្ធនានាត្រូវបានបង្កើតឡើងដោយអង្គការពាណិជ្ជកម្មពិភពលោក។

មាត្រា ១៦
វិន័យរបស់អង្គការពាណិជ្ជកម្មពិភពលោក

អាស្រ័យលើកិច្ចព្រមព្រៀងអនាគតណាមួយ ដែលអាចត្រូវបានព្រមព្រៀងគ្នាអនុលោមតាមការពិនិត្យឡើងវិញនូវកិច្ចព្រមព្រៀងនេះដោយបណ្តាភាគីតាមមាត្រា២៦ បណ្តាភាគីនៅពេលនេះ ព្រមព្រៀង និងអះអាងជាថ្មីអំពីការប្តេជ្ញារបស់ខ្លួនក្នុងការគោរពតាមបទប្បញ្ញត្តិនានានៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោកដែលពាក់ព័ន្ធ និងដែលអាចអនុវត្តបានចំពោះពាណិជ្ជកម្មសេវាកម្ម។

មាត្រា១៧
សហប្រតិបត្តិការ

បណ្តាភាគីត្រូវពង្រឹងកិច្ចប្រឹងប្រែងកិច្ចសហប្រតិបត្តិការនៅក្នុងបណ្តាវិស័យសេវាកម្ម រួមបញ្ចូលទាំងវិស័យនានា ដែលបានព្រមព្រៀងគ្នាទៅវិញទៅមកដោយបណ្តាភាគី។

មាត្រា ១៨
ការបង្កើនការចូលរួមរបស់ប្រទេសសមាជិកអាស៊ានថ្មី

ការបង្កើនការចូលរួមរបស់សមាជិកអាស៊ានថ្មីនៅក្នុងពាណិជ្ជកម្មសេវាកម្ម ត្រូវបានសម្រួលតាមរយៈការសន្យាតាមវិស័យដែលបានចរចារួច ទាក់ទិននឹង:

ក. ការពង្រឹងសមត្ថភាពសេវាកម្មក្នុងស្រុករបស់ពួកគេ និងប្រសិទ្ធភាព និងភាពប្រកួតប្រជែងរបស់សេវា តាមរយៈការប្រើប្រាស់បច្ចេកវិជ្ជាលើមូលដ្ឋានពាណិជ្ជកម្ម

ខ. ការកែលំអការចូលរួមប្រើប្រាស់ខ្សែសង្វាក់ចែកចាយ និងបណ្តាញពត៌មាន

គ. សេរីភាវូបនីយកម្មច្រកចូលទីផ្សារនៃវិស័យ និងរបៀបនៃការផ្គត់ផ្គង់សេវាដែលមានអត្ថប្រយោជន៍សម្រាប់ការនាំចេញរបស់ពួកគេ និង

ឃ. ផ្តល់ភាពទន់ភ្លន់សមស្របដល់ប្រទេសសមាជិកអាស៊ានថ្មី ដើម្បីអាចបើកទូលាយវិស័យក្នុងចំនួនតិចជាង ធ្វើសេរីភាវូបនីយកម្មប្រភេទប្រតិបត្តិការក្នុងចំនួនតិចជាង និងបើកច្រកចូលទីផ្សារជាបណ្តើរៗ អាស្រ័យតាមស្ថានភាពនៃការអភិវឌ្ឍន៍របស់ប្រទេសនីមួយៗ។

ជំពូក III

ការសន្យាតាមវិស័យ

មាត្រា១៩

ច្រកចូលទីផ្សារ

១. ចំពោះច្រកចូលទីផ្សារតាមរយៈរបៀបនៃការផ្គត់ផ្គង់សេវាដែលមានចែងក្នុងមាត្រា១ (ជជ) ភាគីត្រូវផ្តល់ដល់សេវាកម្ម និងអ្នកផ្គត់ផ្គង់សេវារបស់ភាគីផ្សេងទៀតនូវប្រព្រឹត្តិកម្មមិនមានភាពអនុគ្រោះតិចជាងអ្វីដែលបានកំណត់នៅក្នុងលក្ខខ័ណ្ឌ ដែនកំណត់ និងលក្ខខ័ណ្ឌនានាដែលបានព្រមព្រៀងគ្នា និងដែលមានចែងនៅក្នុងតារាងនៃការសន្យារបស់ខ្លួនឡើយ [៨]។

២. នៅក្នុងវិស័យទាំងឡាយដែលការសន្យាច្រកចូលទីផ្សារត្រូវបានធ្វើឡើង វិធានការនានាដែលភាគីមួយ

[៨] ប្រសិនបើភាគីមួយធ្វើការសន្យាច្រកចូលទីផ្សារទាក់ទិននឹងការផ្គត់ផ្គង់សេវា តាមរយៈម៉ូដនៃការផ្គត់ផ្គង់ដែលមានចែងនៅក្នុងមាត្រា ១(ជជ)(i) និងប្រសិនបើ ចលនាឆ្លងព្រំដែននៃមូលធនគឺជាផ្នែកសំខាន់មួយនៃសេវានោះផ្ទាល់ មានន័យថាភាគីនោះក៏បានសន្យាដើម្បីអនុញ្ញាតិឱ្យមានចលនានៃមូលធនប្រភេទនោះផងដែរ។ ប្រសិនបើ ភាគីមួយធ្វើការសន្យាច្រកចូលទីផ្សារទាក់ទិននឹងការផ្គត់ផ្គង់សេវាតាមរយៈម៉ូដនៃការផ្គត់ផ្គង់ដែលមានចែងក្នុងមាត្រា១(ជជ)(iii) មានន័យថាភាគីនោះ បានសន្យាដើម្បីអនុញ្ញាតិឱ្យមានការផ្ទេរមូលធនបែបនោះទៅក្នុងដែនដីរបស់ខ្លួនផងដែរ។

មិនត្រូវរក្សាទុក ឬអនុម័តយកមកប្រើប្រាស់ ទោះក្នុងមូលដ្ឋានតំបន់តូចៗ ឬក្នុងក្របខណ្ឌដែនដីទាំងមូលរបស់ខ្លួនក្តី លើកលែងតែមានការចែងផ្សេងពីនេះនៅក្នុងតារាងនៃការសន្យាតាមវិស័យរបស់ខ្លួន បើមិនដូច្នោះទេ ត្រូវបានកំណត់ដូចខាងក្រោម:

(ក) ការកំណត់លើចំនួនអ្នកផ្គត់ផ្គង់សេវាទោះជាក្នុងទម្រង់ចំនួនកូតា ភាពផ្តាច់មុខ អ្នកផ្គត់ផ្គង់សេវាផ្តាច់មុខ ឬលក្ខខ័ណ្ឌតម្រូវនៃតម្រូវការសេដ្ឋកិច្ច

(ខ) ដាក់ការកំណត់លើតម្លៃសរុបនៃប្រតិបត្តិការសេវាកម្ម ឬទ្រព្យសម្បត្តិ ក្នុងទម្រង់បរិមាណកូតា ឬ លក្ខខ័ណ្ឌតម្រូវនៃតម្រូវការសេដ្ឋកិច្ច

(គ) ដាក់ការរឹតត្បិតលើបរិមាណសរុបនៃប្រតិបត្តិការសេវាកម្ម ឬលើបរិមាណសរុបនៃទិន្នផលសេវាកម្មគិតជាឯកតាលេខនព្វន្តក្នុងទម្រង់កូតា ឬលក្ខខណ្ឌតម្រូវនៃតម្រូវការសេដ្ឋកិច្ច ។

(ឃ) ដាក់ការកំណត់បរិមាណសរុបនៃរូបវន្តបុគ្គលដែលអាចជួលមកធ្វើការនៅក្នុងវិស័យសេវាកម្មណាមួយ ឬការកំណត់លើរូបវន្តបុគ្គលដែលអ្នកផ្គត់ផ្គង់សេវាអាចជួលមកធ្វើការ និងរូបវន្តបុគ្គលដែលចាំបាច់ និងមានការទាក់ទិនផ្ទាល់ទៅនឹងការផ្គត់ផ្គង់សេវាណាមួយក្នុងទំរង់បរិមាណកូតា ឬលក្ខខណ្ឌតម្រូវនៃតម្រូវការសេដ្ឋកិច្ច

(ង) វិធានការទាំងឡាយដែលរឹតត្បិត ឬតម្រូវឱ្យមានប្រភេទនីតិបុគ្គលណាមួយ ឬត្រូវចម្រុះទុនដែលតាមរយៈនោះ អ្នកផ្គត់ផ្គង់សេវាធ្វើការផ្គត់ផ្គង់សេវាបាន និង

(ច) ដាក់ការកំណត់លើចំណែកមូលធនបរទេស ក្នុងន័យជាការកំណត់អត្រាភាគរយអតិបរមាសម្រាប់ភាគទុនបរទេស ឬលើតម្លៃសរុបនៃវិនិយោគបរទេសនីមួយៗ ឬលើតម្លៃសរុបនៃវិនិយោគបរទេសសរុប ។

មាត្រា ២០

ប្រព្រឹត្តិកម្មជាតិ

១. នៅក្នុងវិស័យនានាដែលមានចែងក្នុងតារាងនៃការសន្យារបស់ខ្លួន និងអាស្រ័យតាមបណ្តាលក្ខខ័ណ្ឌ និងគុណវុឌ្ឍិកម្មដែលចែងក្នុងនោះ ភាគីនីមួយៗត្រូវផ្តល់ដល់សេវាកម្ម និងអ្នកផ្គត់ផ្គង់សេវានៃភាគីផ្សេងទៀតពាក់

---

[៩] វាក្យខ័ណ្ឌរង២(គ) នៃមាត្រានេះ មិនគ្របដណ្តប់លើវិធានការនានារបស់ភាគីដែលរឹតត្បិតប្រភពទុនសំរាប់ការផ្គត់ផ្គង់សេវាឡើយ ។

ព័ន្ធនឹងវិធានការទាំងអស់ដែលជះឥទ្ធិពលដល់ការផ្គត់ផ្គង់សេវា នូវប្រព្រឹត្តិកម្មមិនមានភាពអនុគ្រោះតិចជាងអ្វីដែលបានផ្តល់ដល់សេវាកម្ម និងអ្នកផ្គត់ផ្គង់សេវាដូចគ្នារបស់ប្រទេសខ្លួនឡើយ [១០] ។

២. ភាគីមួយអាចបំពេញបានតាមលក្ខខណ្ឌតម្រូវនៃកថាខណ្ឌ១ តាមរយៈការផ្តល់ដល់សេវាកម្ម និងអ្នកផ្គត់ផ្គង់សេវានៃភាគីដទៃទៀតនូវប្រព្រឹត្តិកម្មដូចគ្នា ឬខុសគ្នា ទៅនឹងប្រព្រឹត្តិកម្មផ្តល់ដល់សេវាកម្ម និងអ្នកផ្គត់ផ្គង់សេវាដូចគ្នារបស់ជាតិខ្លួនផ្ទាល់ ។

៣. ប្រព្រឹត្តិកម្មដូចគ្នា ឬខុសគ្នា ត្រូវបានចាត់ទុកថាមានភាពអនុគ្រោះតិចជាង ប្រសិនបើវាបានកែប្រែលក្ខខណ្ឌប្រកួតប្រជែង ដោយផ្តល់ផលប្រយោជន៍ចំពោះសេវាកម្ម និងអ្នកផ្គត់ផ្គង់សេវារបស់ភាគីមួយធៀបនឹងសេវាកម្ម ឬអ្នកផ្គត់ផ្គង់សេវាដូចគ្នានៃភាគីមួយផ្សេងទៀត ។

មាត្រា ២១
ការសន្យាបន្ថែម

បណ្តាភាគីអាចចរចាលើការសន្យាដែលពាក់ព័ន្ធនឹងវិធានការនានាដែលជះឥទ្ធិពលដល់ពាណិជ្ជកម្មសេវាកម្ម ដែលមិនមែនជាកម្មវត្ថុការដាក់ចូលក្នុងតារាងនៃការសន្យាធ្វើឡើងនៅក្រោមមាត្រា១៩ ឬមាត្រា២០ រួមបញ្ចូលនូវវិធានការនានាពាក់ព័ន្ធនឹងគុណវុឌ្ឍិ បទដ្ឋាន ឬអាជ្ញាប័ណ្ណ។ ការសន្យាទាំងនេះត្រូវសរសេរនៅក្នុងតារាងនៃការសន្យារបស់ភាគី ។

មាត្រា ២២
តារាងនៃការសន្យាតាមវិស័យ

១. ភាគីនីមួយៗ ត្រូវបង្កើតតារាងនៃការសន្យាតាមវិស័យ ដែលខ្លួនធ្វើឡើងនៅក្រោមមាត្រា១៩ មាត្រា២០ និងមាត្រា២១ ។ ចំពោះវិស័យនានាដែលការសន្យា ត្រូវបានធ្វើឡើង តារាងនៃការសន្យានីមួយៗត្រូវចែងអំពីៈ

(ក) លក្ខខ័ណ្ឌ ការកំណត់ និងបណ្តាលក្ខខណ្ឌច្រកចូលទីផ្សារ

(ខ) លក្ខខ័ណ្ឌ និងគុណវុឌ្ឍិកម្មលើប្រព្រឹត្តិកម្មជាតិ

(គ) ការទទួលយកផ្សេងៗទាក់ទិននឹងការសន្យាបន្ថែម និង

---

[១០] ការសន្យាតាមវិស័យដែលធ្វើឡើងនៅក្រោមមាត្រានេះ មិនត្រូវបកស្រាយថា ជាការតម្រូវឱ្យភាគីនានាផ្តល់សំណងខូចខាតចំពោះវិឧត្តមភាពប្រកួតប្រជែងដែលផ្សារភ្ជាប់ជាមួយវា កើតចេញពីចរិតលក្ខណៈបរទេសនៃសេវាកម្ម ឬអ្នកផ្គត់ផ្គង់សេវាពាក់ព័ន្ធឡើយ ។

(ឃ) ក្របខ័ណ្ឌពេលវេលាសមស្របសំរាប់អនុវត្តន៍ការសន្យាទាំងនេះ ប្រសិនបើអាចធ្វើទៅបាន

(ង) កាលបរិច្ឆេទនៃការចូលជាធរមាននៃការសន្យាទាំងនោះ ។

២. វិធានការនានាដែលមិនស្របនឹងមាត្រា១៩ ត្រូវចុះនៅក្នុងតារាងដែលពាក់ព័ន្ធនឹងមាត្រា ១៩ និងវិធានការនានាដែលមិនស្របនឹងមាត្រា២០ ត្រូវចុះក្នុងតារាងដែលទាក់ទិននឹងមាត្រា២០ ។

៣. តារាងនៃការសន្យា ត្រូវភ្ជាប់ជាឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងនេះ និងជាផ្នែកទាំងមូលនៃកិច្ចព្រមព្រៀងនេះ ។

មាត្រា ២៣
ការអនុវត្ត និងការផ្តល់ការសន្យា

១. ភាគីកូរ៉េត្រូវបង្កើតតារាងនៃការសន្យាតាមវិស័យតែមួយគត់តាមមាត្រា២២ ហើយត្រូវអនុវត្តតារាងនៃការសន្យានេះ ចំពោះប្រទេសសមាជិកអាស៊ានទាំងអស់ ។

២. ប្រទេសសមាជិកអាស៊ាននីមួយៗ ត្រូវបង្កើតតារាងនៃការសន្យាតាមវិស័យរៀងៗខ្លួនតាមមាត្រា២២ និងត្រូវអនុវត្តតារាងនៃការសន្យានេះចំពោះភាគីកូរ៉េ និងសមាជិកអាស៊ានដទៃទៀត ។

មាត្រា ២៤
សេរីភាវូបនីយកម្មជាបណ្តើរៗ

ក្នុងការពិនិត្យឡើងវិញដោយអនុលោមតាមមាត្រា២៦ បណ្តាភាគីត្រូវចូលរួមក្នុងវគ្គចរចាជាបន្តបន្ទាប់ ដើម្បីចរចាបន្តលើកញ្ចប់បន្ថែមនៃការសន្យាតាមវិស័យនៅក្រោមកិច្ចព្រមព្រៀងនេះ ដើម្បីធ្វើសេរីភាវូបនីយកម្មជាបណ្តើរៗ ចំពោះការធ្វើពាណិជ្ជកម្មសេវាកម្មរវាងបណ្តាភាគី ។

មាត្រា ២៥
ការកែប្រែតារាងនៃការសន្យា

១. ភាគីមួយអាចកែប្រែ ឬដកចេញនូវការសន្យាណាមួយនៅក្នុងតារាងនៃការសន្យារបស់ខ្លួននៅពេលណាមួយក៏បាន បន្ទាប់ពីអំឡុងពេលបីឆ្នាំបានកន្លងផុតទៅ គិតចាប់ពីកាលបរិច្ឆេទដែលការសន្យានោះបានចូលជាធរមាន ឱ្យតែ៖

(ក) ភាគីនោះជូនដំណឹងដល់បណ្តាភាគី និងគណៈកម្មការអនុវត្តអំពីចេតនារបស់ខ្លួនក្នុងការកែប្រែ ឬដកចេញនូវការសន្យាមិនហួសពីបីខែមុនកាលបរិច្ឆេទដែលមានបំណងចាប់ផ្តើមអនុវត្តការកែប្រែ ឬ ដកចេញរបស់ខ្លួន និង

(ខ) ភាគីនោះចូលរួមចរចាជាមួយភាគីរងការប៉ះពាល់ ដើម្បីព្រមព្រៀងគ្នាអំពីសំណង ទូទាត់ចាំបាច់។

២. ដើម្បីសម្រេចបាននូវសំណងទូទាត់មួយ បណ្តាភាគីត្រូវធានាថាកម្រិតទូទៅនៃការសន្យាដែលមានផលប្រយោជន៍ទៅវិញទៅមកមិនត្រូវមានភាពអនុគ្រោះចំពោះពាណិជ្ជកម្មតិចជាងអ្វីដែលបានផ្តល់នៅក្នុងតារាងនៃការសន្យា ដែលមានមុនពេលចាប់ផ្តើមចរចាបែបនេះឡើយ។

៣. សំណងទូទាត់ណាមួយដែលធ្វើឡើងស្របតាមមាត្រានេះ នឹងត្រូវផ្តល់ជូនលើមូលដ្ឋានមិនរើសអើងចំពោះភាគីទាំងអស់។

៤.ប្រសិនបើភាគីពាក់ព័ន្ធមិនអាចសម្រេចបាននូវកិច្ចព្រមព្រៀងស្តីពីសំណងទូទាត់ណាមួយទេនោះ បញ្ហានេះនឹងត្រូវដោះស្រាយដោយវេទិកាមជ្ឈត្តការ[១១]។ ភាគីកែប្រែមិនត្រូវអនុវត្តការកែប្រែ ឬដកចេញការសន្យារបស់ខ្លួនឡើយដោយត្រូវចាំរហូតទាល់តែភាគីនោះបានធ្វើសំណងទូទាត់ស្របតាមការសម្រេចរបស់មជ្ឈត្តការរួចរាល់សិន។

៥. ប្រសិនបើភាគីកែប្រែ អនុវត្តគំរោងកែប្រែ ឬដកចេញការសន្យារបស់ខ្លួន មិនស្របតាមការសម្រេចរបស់មជ្ឈត្តការទេនោះ ភាគីនានាដែលចូលរួមក្នុងមជ្ឈត្តការអាចកែប្រែ ឬដកចេញនូវផលប្រយោជន៍នានាដែលសមមូលស្មើរតែទាំងស្រុងអនុលោមតាមការសម្រេចទាំងនោះ។ ទោះបីជាមានចែងក្នុងមាត្រា២៣ ក៏ដោយ ក៏ការកែប្រែ ឬដកចេញបែបនេះ អាចត្រូវបានអនុវត្តតែទៅលើភាគីកែប្រែប៉ុណ្ណោះ។

ជំពូក IV:
អវសានប្បញ្ញត្តិ

មាត្រា ២៦
ការពិនិត្យឡើងវិញ

---

[១១] គណៈកម្មាធិការទទួលបន្ទុកអនុវត្ត ត្រូវបង្កើតនីតិវិធីសំរាប់មជ្ឈត្តការក្នុងពេលវេលាសមស្រប។

រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន និងរដ្ឋមន្ត្រីពាណិជ្ជកម្មកូរ៉េ ឬតំណាងរបស់ពួកគេ ត្រូវជួបប្រជុំក្នុងរយៈពេលមួយឆ្នាំ គិតពីកាលបរិច្ឆេទនៃការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ហើយបន្ទាប់ពីនោះត្រូវជួបគ្នារៀងរាល់ពីរឆ្នាំម្តង ឬបើមិនដូច្នោះទេត្រូវជួបគ្នាក្នុងចន្លោះពេលសមស្រប ដើម្បីពិនិត្យឡើងវិញនូវកិច្ចព្រមព្រៀងនេះ សំរាប់គោលបំណងនៃការពិចារណាលើការចាត់វិធានការបន្ថែមទៀតសំរាប់សេរីភាវូបនីយកម្មសេវាកម្ម និងដើម្បីបង្កើតវិន័យ និងចរចាលើកិច្ចព្រមព្រៀងនានាស្តីពីបញ្ហាដែលមានចែងនៅក្នុងមាត្រា១៦ ឬលើបញ្ហាពាក់ព័ន្ធដទៃទៀត តាមដែលអាចព្រមព្រៀងគ្នា។

មាត្រា ២៧
បទប្បញ្ញត្តិផ្សេងៗ

១. កិច្ចព្រមព្រៀងនេះ ត្រូវរួមបញ្ចូលនូវបណ្តាឧបសម្ព័ន្ធ និងមាតិកានានានៅក្នុងនោះ ដែលបង្កើតជាផ្នែកទាំងមូលនៃកិច្ចព្រមព្រៀងនេះ និងរាល់លិខិតុបករណ៍គតិយុត្តិទាំងអស់ដែលបានព្រមព្រៀងគ្នាស្របតាមកិច្ចព្រមព្រៀងនេះ។

២. ឧបសម្ព័ន្ធស្តីពីសេវាហិរញ្ញវត្ថុ ត្រូវក្លាយជាផ្នែកទាំងមូលនៃកិច្ចព្រមព្រៀងនេះ។

៣. ឧបសម្ព័ន្ធស្តីពីទូរគមនាគមន៍ នៃកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម នឹងត្រូវបញ្ចូលទៅក្នុងកិច្ចព្រមព្រៀងនេះ បើសិនមានការត្រូវផ្លាស់ប្តូរ។

៤. លើកលែងតែមានការចែងផ្សេងពីនេះនៅក្នុងកិច្ចព្រមព្រៀងនេះ បើមិនដូច្នោះទេ កិច្ចព្រមព្រៀងនេះ ឬសកម្មភាពណាមួយដែលធ្វើឡើងក្រោមវា មិនត្រូវប៉ះពាល់ឬមោឃកម្មដល់សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីមួយនៅតាមក្រោមកិច្ចព្រមព្រៀងដែលមានស្រាប់ ដែលភាគីនោះជាហត្ថលេខីឡើយ។

៥. ប្រទេសសមាជិកអាស៊ានអាចចូលរួមក្នុងការរៀបចំទ្វេភាគីដោយឡែកជាមួយភាគីកូរ៉េ ពាក់ព័ន្ធនឹងសហផលិតកម្មកម្មវិធីផ្សាយ ស្របតាមកិច្ចព្រមព្រៀងនេះ ហើយការរៀបចំទ្វេភាគីបែបនេះ ត្រូវអនុវត្តចំពោះតែភាគីនោះប៉ុណ្ណោះ។

មាត្រា២៨
វិសោធនកម្ម

កិច្ចព្រមព្រៀងនេះ អាចត្រូវបានធ្វើវិសោធនកម្មដោយមានការព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរពីបណ្តាភាគីហើយវិសោធនកម្មទាំងនោះ នឹងត្រូវចូលជាធរមាននៅកាលបរិច្ឆេទ ឬបណ្តាកាលបរិច្ឆេទដែលបានព្រមព្រៀងគ្នាដោយបណ្តាភាគី ។

មាត្រា ២៩
ការដោះស្រាយវិវាទ

លើកលែងតែមានការចែងផ្សេងពីនេះនៅក្នុងកិច្ចព្រមព្រៀងនេះ វិវាទណាមួយពាក់ព័ន្ធនឹងការបកស្រាយ ការអនុវត្ត ឬការប្រតិបត្តិកិច្ចព្រមព្រៀងនេះ ត្រូវបានដោះស្រាយតាមរយៈនីតិវិធី និងយន្តការនានា ដូចមានចែងក្នុងកិច្ចព្រមព្រៀងស្តីពីយន្តការដោះស្រាយវិវាទតាមកិច្ចព្រមព្រៀងក្របខ័ណ្ឌ ។

មាត្រា ៣០
ការបដិសេធផលប្រយោជន៍

ភាគីមួយអាចបដិសេធផលប្រយោជន៍នៃកិច្ចព្រមព្រៀងនេះ:

ក. ចំពោះការផ្តត់ផ្គង់សេវាមួយ ប្រសិនបើរកឃើញថា សេវានោះត្រូវបានផ្គត់ផ្គង់ចេញមកពី ឬទៅក្នុងដែនដីនៃប្រទេសមិនមែនជាភាគី

ខ. ក្នុងករណីនៃការផ្គត់ផ្គង់សេវាដឹកជញ្ជូនផ្លូវសមុទ្រ ប្រសិនបើរកឃើញថា សេវាត្រូវបានផ្គត់ផ្គង់:

i. ដោយនាវាដែលបានចុះបញ្ជីតាមច្បាប់របស់ប្រទេសមិនមែនភាគី និង
ii. ដោយបុគ្គលនៃប្រទេសមិនមែនជាភាគី ដែលប្រតិបត្តិការ និង/ឬប្រើប្រាស់នាវានោះទាំងមូល ឬដោយផ្នែក ។

គ. ចំពោះអ្នកផ្គង់ផ្គង់សេវាដែលជានីតិបុគ្គល ប្រសិនបើរកឃើញថា នីតិបុគ្គលនោះមិនមែនជាអ្នកផ្គត់ផ្គង់សេវានៃភាគីម្ខាងទៀត ។

មាត្រា ៣១
ការចូលជាធរមាន

១. កិច្ចព្រមព្រៀងនេះ ត្រូវចូលជាធរមាននៅថ្ងៃទីមួយ នៃខែទីពីរ បន្ទាប់ពីកាលបរិច្ឆេទដែលយ៉ាងហោចណាស់មានប្រទេសសមាជិកអាស៊ានមួយ និងភាគីកូរ៉េ បានជូនដំណឹងជាលាយលក្ខណ៍អក្សរទៅបណ្តាភាគីផ្សេងទៀតទាំងអស់អំពីការបំពេញនីតិវិធីក្នុងស្រុករបស់ខ្លួនចប់សព្វគ្រប់ ។

២. នៅពេលបំពេញចប់សព្វគ្រប់នូវនីតិវិធីក្នុងស្រុករបស់ខ្លួនសំរាប់ការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះរួចហើយ ភាគីត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ភាគីដទៃទៀតទាំងអស់ ។

៣. នៅពេលណាដែលភាគីមិនអាចបញ្ចប់នីតិវិធីក្នុងស្រុករបស់ខ្លួនសំរាប់ការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ តាមកាលបរិច្ឆេទដែលបានកំណត់ក្នុងកថាខ័ណ្ឌ១ទេនោះ កិច្ចព្រមព្រៀងនេះនឹងចូលជាធរមានសំរាប់ភាគីនោះ ក្នុងរយៈពេល៣០ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទដែលភាគីនោះបានជូនដំណឹងជាលាយលក្ខណ៍អក្សរទៅភាគីដទៃទៀតទាំងអស់អំពីការបញ្ចប់នីតិវិធីផ្ទៃក្នុងរបស់ខ្លួន។ ទោះបីជាយ៉ាងណាក៏ដោយ ភាគីពាក់ព័ន្ធនោះត្រូវបានភ្ជាប់កាតព្វកិច្ចនូវលក្ខខ័ណ្ឌដូចគ្នាតាមកិច្ចព្រមព្រៀងនេះ រួមបញ្ចូលនូវការសន្យាបន្ថែមនានាដែលអាចត្រូវបានធ្វើឡើងដោយបណ្តាភាគីនានាតាមកិច្ចព្រមព្រៀងនេះនៅខណៈពេលនៃការជូនដំណឹងនោះ ទោះបីជាភាគីនោះបានជូនដំណឹងជាលាយលក្ខណ៍អក្សរទៅបណ្តាភាគីដទៃទៀតទាំងអស់អំពីការបញ្ចប់នីតិវិធីក្នុងស្រុករបស់ខ្លួនមុនកាលបរិច្ឆេទនៃការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះក៏ដោយ ។

មាត្រា ៣២
ការតម្កល់ទុក

សំរាប់បណ្តាប្រទេសសមាជិកអាស៊ាន កិច្ចព្រមព្រៀងនេះត្រូវតម្កល់ទុកនៅនឹងអគ្គលេខាធិការអាស៊ានជាអ្នកដែលត្រូវផ្តល់ជាបន្ទាន់នូវច្បាប់ចម្លងបញ្ជាក់ថាបានចម្លងត្រឹមត្រូវតាមច្បាប់ដើមជូនប្រទេសសមាជិកអាស៊ាននីមួយៗ ។

ជាសក្ខីកម្ម ហត្ថលេខីខាងក្រោម ដោយមានការអនុញ្ញាតត្រឹមត្រូវពីរដ្ឋាភិបាលរៀងៗខ្លួន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មសេវាកម្មតាមកិច្ចព្រមព្រៀងក្របខណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍[១២] និងសាធារណរដ្ឋកូរ៉េ ។

ធ្វើនៅ សឹង្ហបុរី ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ ចំនួនពីរច្បាប់ដើមជាភាសាអង់គ្លេស ។

---

[១២] បណ្តាភាគីឯកភាពគ្នាថា រាជាណាចក្រថៃឡង់ដ៍អាចចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាកម្មនៅពេលក្រោយបាន ខណៈដែលនីតិវិធីរដ្ឋសភារបស់ប្រទេសនេះ ត្រូវបានបំពេញចប់សព្វគ្រប់ ។

តំណាងរដ្ឋាភិបាលប្រ៊ុយណេដារូស្សាឡាម

លឹម ចុកសេង

រដ្ឋមន្ត្រីទីពីរនៃក្រសួងការបរទេស និងពាណិជ្ជកម្ម

តំណាងរាជរដ្ឋាភិបាលកម្ពុជា

ចម ប្រសិទ្ធ

(ii) for measures to ensure the stability of the exchange rate including to prevent speculative capital flows, such measures shall be no more than necessary, and phased out within one year or when conditions no longer justify their institution or maintenance; and

(iii) for measures to ensure the stability of the exchange rate including to prevent speculative capital flows, such measures shall be applied on a Most-Favoured-Nation basis.

(b) Nothing in this Agreement shall be construed to require a Party to disclose information relating to the affairs and accounts of individual customers or any confidential or proprietary information in the possession of public entities.

3. **Recognition**

(a) A Party may recognise prudential measures of any other country in determining how the Party's measures relating to financial services shall be applied. Such recognition, which may be achieved through harmonisation or otherwise, may be based upon an agreement or arrangement with the country concerned or may be accorded autonomously.

(b) A Party that is a party to such an agreement or arrangement referred to in subparagraph (a), whether future or existing, shall afford adequate opportunity for other interested Parties to negotiate their accession to such agreements or arrangements, or to negotiate comparable ones with it, under circumstances in which there would be equivalent regulation, oversight, implementation of such regulation, and, if appropriate,

[1] The measures to ensure the stability of the exchange rate including to prevent speculative capital flows shall not be adopted or maintained for the purpose of protecting a particular sector.

procedures concerning the sharing of information between the parties to the agreement or arrangement. Where a Party accords recognition autonomously, it shall afford adequate opportunity for any other Party to demonstrate that such circumstances exist.

(c) Where a Party is contemplating according recognition to prudential measures of any other country, paragraph 4(b) of Article 7 shall not apply.

4. **Dispute Settlement**

Panels for disputes on prudential issues and other financial matters shall have the necessary expertise relevant to the specific financial service under dispute.

5. **Definitions**

For the purposes of this Annex:

(a) **A financial service** is any service of a financial nature offered by a financial service supplier of a Party. Financial services include all insurance and insurance-related services, and all banking and other financial services (excluding insurance). Financial services include the following activities:

Insurance and insurance-related services

(i) Direct insurance (including co-insurance):

(A) life
(B) non-life

(ii) Reinsurance and retrocession;

(iii) Insurance intermediation, such as brokerage and agency;

(iv) Services auxiliary to insurance, such as consultancy, actuarial, risk assessment and claim settlement services.

Banking and other financial services (excluding insurance)

(v) Acceptance of deposits and other repayable funds from the public;

(vi) Lending of all types, including consumer credit, mortgage credit, factoring and financing of commercial transaction;

(vii) Financial leasing;

(viii) All payment and money transmission services, including credit, charge and debit cards, travellers cheques and bankers drafts;

(ix) Guarantees and commitments;

(x) Trading for own account or for account of customers, whether on an exchange, in an over-the-counter market or otherwise, the following:

(A) money market instruments (including cheques, bills, certificates of deposits);
(B) foreign exchange;
(C) derivative products including, but not limited to, futures and options;
(D) exchange rate and interest rate instruments, including products such as swaps, forward rate agreements;
(E) transferable securities;
(F) other negotiable instruments and financial assets, including bullion.

(xi) Participation in issues of all kinds of securities, including underwriting and placement as agent (whether publicly or privately) and provision of services related to such issues;

(xii) Money broking;

(xiii) Asset management, such as cash or portfolio management, all forms of collective investment management, pension fund management, custodial, depository and trust services;

(xiv) Settlement and clearing services for financial assets, including securities, derivative products, and other negotiable instruments;

(xv) Provision and transfer of financial information, and financial data processing and related software by suppliers of other financial services;

(xvi) Advisory, intermediation and other auxiliary financial services on all the activities listed in subparagraphs (v) through (xv), including credit reference and analysis, investment and portfolio research and advice, advice on acquisitions and on corporate restructuring and strategy.

(b) **A financial service supplier** means any natural or juridical person of a Party wishing to supply or supplying financial services but the term "financial service supplier" does not include a public entity.

(c) **Public entity** means:

(i) a government, a central bank or a monetary authority, of a Party, or an entity owned or controlled by a Party, that is principally engaged in carrying out governmental functions or activities for governmental purposes, not including an entity principally engaged in supplying financial services on commercial terms; or

(ii) a private entity, performing functions normally performed by a central bank or monetary authority, when exercising those functions.

ព្រះរាជក្រឹត្យ

នស/រកត/១០០៩/៩៩២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ផ្តល់សញ្ជាតិខ្មែរ ដោយអាពាហ៍ពិពាហ៍ដល់លោក **ជូលៀន ហែនសិន** (JULIAN HANSEN) ជនជាតិញូវែលសេឡង់ សញ្ជាតិញូវែលសេឡង់ កើតថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ១៩៦៨ នៅហែនឌឺសុន ប្រទេសញូវែលសេឡង់ ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៩១០.១០០៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ. ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៩

លេខៈ ៩៣៦ ច.ល
ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible]

ព្រះរាជក្រឹត្យ

នស/រកត/១០០៩/៩៩៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- *បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨* ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក អ៊ុង ប៊ីហ្វត (ONG BEE HUAT) ជនជាតិសិង្ហបុរី សញ្ជាតិសិង្ហបុរី កើតថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៦៩ នៅប្រទេសសិង្ហបុរី ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៩១០.១០១០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៩

លេខ: ៩៣៧ ច.ល
ចម្លងចេញពីច្បាប់ដើម
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុន ចិនតេន

ព្រះរាជក្រឹត្យ

នស/រកត/១០០៩/១០០៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

តែងតាំង

លោក ឃី គីមលន់

ជា

ឧកញ៉ា

៣រ.ច. ០៩១០. ១០២៥

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០០៩ លេខៈ ៩៨៦ ច.ល

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៩
[illegible]ទីស្តីការគណៈរដ្ឋាភិបាល
[illegible] នគេន

ព្រះរាជក្រឹត្យ

នស/រកត/១០០៩/១០៧០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៤ នៃរដ្ឋសភា នាថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ និងថ្នាក់ដឹកនាំរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២០៣/០០៣ ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការ នៃក្រុមនីតិប្បញ្ញត្តិ
- បានទ្រង់យល់សេចក្តីសម្រេចលេខ ០២២ រស ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីដាលការណ៍បញ្ចូលមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា ទៅក្នុងក្របខ័ណ្ឌមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ
- បានទ្រង់យល់ច្បាប់ស្តីពីថវិកាប្រចាំឆ្នាំ២០០៩ របស់រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា**

ត្រាស់បង្គាប់

មាត្រា១ .- ត្រូវបានតម្លើងថ្នាក់មួយថ្នាក់ ក្នុងឋានន្តរសក្តិឧត្តមអភិបាល ជូនមន្ត្រីរាជការក្របខ័ណ្ឌអគ្គលេខាធិការដ្ឋានរដ្ឋសភា នៃមន្ត្រីរាជការក្រុមនីតិប្បញ្ញត្តិ ចាប់ពីថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៩ តទៅ ដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តម **ម៉ូច សុខហ៊ាន** អត្តលេខ : ០០០៨ ពីឧត្តមអភិបាល ថ្នាក់លេខ ២ ទៅជា ឧត្តមអភិបាល ថ្នាក់លេខ ១

ឯកឧត្តម **ឈឹម ស៊ីដេឈីស** អត្តលេខ : ០០២០ ពីឧត្តមអភិបាល ថ្នាក់លេខ ២ ទៅជា ឧត្តមអភិបាល ថ្នាក់លេខ ១

ROYAUME DU CAMBODGE
MINISTRE DU PALAIS ROYAL

៣- ឯកឧត្តម **ញ៉ែម សារឿយ** អត្តលេខ : ០០១១ ពី ឧត្តមអភិបាល ថ្នាក់លេខ ២ ទៅជា ឧត្តមអភិបាល ថ្នាក់លេខ ១

៤- ឯកឧត្តម **អ៊ុយ ទិសាល** អត្តលេខ : ០០៨៨ ពី ឧត្តមអភិបាល ថ្នាក់លេខ ២ ទៅជា ឧត្តមអភិបាល ថ្នាក់លេខ ១

៥- ឯកឧត្តម **ឡៅ ម៉ុនលី** អត្តលេខ : ០១៤៧ ពី ឧត្តមអភិបាល ថ្នាក់លេខ ២ ទៅជា ឧត្តមអភិបាល ថ្នាក់លេខ ១

៦- ឯកឧត្តម **កែម សុផុនណា** អត្តលេខ : ០២១៨ ពី ឧត្តមអភិបាល ថ្នាក់លេខ ៣ ទៅជា ឧត្តមអភិបាល ថ្នាក់លេខ ២

៧- លោកជំទាវ **ស៊ួន ឡេងអាន** អត្តលេខ : ០០២៤ ពី ឧត្តមអភិបាល ថ្នាក់លេខ ៣ ទៅជា ឧត្តមអភិបាល ថ្នាក់លេខ ២

៨- អ្នកអង្គម្ចាស់ **នរោត្តម ដារ៉ាវ៉េត** អត្តលេខ : ០១៧៥ ពី ឧត្តមអភិបាល ថ្នាក់លេខ ៤ ទៅជា ឧត្តមអភិបាល ថ្នាក់លេខ ៣

៩- ឯកឧត្តម **ស្រី សារ៉េត** អត្តលេខ : ០៥១៥ ពី ឧត្តមអភិបាល ថ្នាក់លេខ ៦ ទៅជា ឧត្តមអភិបាល ថ្នាក់លេខ ៥

មាត្រា២ .- សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុក អនុវត្តព្រះរាជក្រឹត្យនេះ ។

៣៤.០៩១០.១០៤១

ព្រះហស្តលេខា និងព្រះរាជលញ្ចករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៩

លេខ: ៩៨៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែ វិច្ឆិកា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ស៊ុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១០០៩/១០៣៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

តែងតាំង

លោក ហុង ឆាយ

ជា

ឧកញ៉ា

៣រល.០៩១០.១០៥៦

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០០៩

លេខ:៩៧៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible] ចិនកេង

ព្រះរាជក្រឹត្យ

នស/រកត/១០០៩/១០៣៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និងកីឡា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **កើ ណៃលាង** ជាអនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ២ : រាល់បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៩២០.១០៥៧

លេខ:៩៧១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែវិច្ឆិកា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០០៩

ស៊ិន ជិនគេន

ព្រះរាជក្រឹត្យ

នស/រកត/១០០៩/១០៣៧

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្ដមសេនីយ៍ទោ** ជូនឧត្ដមសេនីយ៍ត្រី **ឈឹម សាខន** អត្តលេខ ០៤៤០ នាយនគរបាលជាតិជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ។

មាត្រា ២ : សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣១ល.០៩១០.១០៥៩

លេខៈ ៩៧៣ ច.ល

ដើម្បីចម្លងចែក

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០០៩

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៩

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

ស៊ុន ចាន់ថុន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១២៩៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការដំឡើងឋានន្តរស័ក្តិ នាយទាហាន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យ ក្រសួងការពារជាតិ មកជា អគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០៩ ស្តីពីការ បង្កើតបញ្ជាការដ្ឋានអង្គរក្ស
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា១ : ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម :

១-វរសេនីយ៍ទោ	ញ៉ឹក	ញ៉ាក់	អត្តលេខ ០៣២៥៨៦	នាយទាហានការពារផ្ទាល់
២-វរសេនីយ៍ទោ	ទ្រី	ឫទ្ធី	អត្តលេខ ០១១៧៨៤	នាយទាហានការពារផ្ទាល់
៣-វរសេនីយ៍ទោ	សីវុទ្ធ	កុសល	អត្តលេខ ២២៧២០៥	នាយទាហានការពារផ្ទាល់
៤-វរសេនីយ៍ទោ	ស៊ិន	សារឿន	អត្តលេខ ០១១៦៨០	នាយទាហានការពារផ្ទាល់
៥-វរសេនីយ៍ទោ	ឃិន	ហេង	អត្តលេខ ២០៩៩៨៣	នាយទាហានការពារផ្ទាល់
៦-វរសេនីយ៍ទោ	ឡុង	ជា	អត្តលេខ ០១៧៣៥០	នាយទាហានការពារផ្ទាល់
៧-វរសេនីយ៍ទោ	ហ៊ុន	រិន	អត្តលេខ ១៤៦២៦៦	នាយទាហានការពារផ្ទាល់
៨-វរសេនីយ៍ទោ	ទេព	វណ្ណា	អត្តលេខ ១៦២៣០៦	នាយទាហានការពារផ្ទាល់

៩-វរសេនីយ៍ទោ	កែវ	ពិសិដ្ឋ	អត្តលេខ ០០៥២៧៩	នាយទាហានការពារផ្ទាល់
១០-វរសេនីយ៍ទោ	ព្រហ្ម	បូរ៉ា	អត្តលេខ ០២១១៩២	នាយទាហានការពារផ្ទាល់
១១-វរសេនីយ៍ទោ	យ៉េង	សារឿន	អត្តលេខ ០០៤០១៧	នាយទាហានការពារផ្ទាល់
១២-វរសេនីយ៍ទោ	ថៅ	គឿន	អត្តលេខ ០១១៧៦៨	នាយទាហានការពារផ្ទាល់
១៣-វរសេនីយ៍ទោ	ញ៉ៀម	រ៉ា	អត្តលេខ ១៧៩៤៧៣	នាយទាហានការពារផ្ទាល់
១៤-វរសេនីយ៍ទោ	ឡុន	វីរៈ	អត្តលេខ ១៣៤៦៧៨	នាយទាហានការពារផ្ទាល់
១៥-វរសេនីយ៍ទោ	ហែម	ឡុងគង់	អត្តលេខ ១៣៣៣១៩	នាយទាហានការពារផ្ទាល់
១៦-វរសេនីយ៍ទោ	ឃួន	សម្បត្តិ	អត្តលេខ ០៦១៨៤៦	នាយទាហានការពារផ្ទាល់
១៧-វរសេនីយ៍ទោ	អេង	ហ៊ី	អត្តលេខ ០១២៤៤៧	នាយទាហានការពារផ្ទាល់
១៨-វរសេនីយ៍ទោ	ឆឹម	ស៊ីណារក្ស	អត្តលេខ ១១៤២៩០	នាយទាហានការពារផ្ទាល់
១៩-វរសេនីយ៍ទោ	ម៉ែន	ហ៊ុយ	អត្តលេខ ០១១៧៥៩	នាយទាហានការពារផ្ទាល់
២០-វរសេនីយ៍ទោ	ម៉ាក	សារ៉ាត់	អត្តលេខ ០៤៣៨៩៩	នាយទាហានការពារផ្ទាល់
២១-វរសេនីយ៍ទោ	ញឹម	សាវឿន	អត្តលេខ ១៦៨០៦៤	នាយទាហានការពារផ្ទាល់
២២-វរសេនីយ៍ទោ	នួន	ណារិទ្ធ	អត្តលេខ ២៣២១៤៦	នាយទាហានការពារផ្ទាល់
២៣-វរសេនីយ៍ទោ	ចាន់	សំអាង	អត្តលេខ ០៤០៦៦៣	នាយទាហានការពារផ្ទាល់
២៤-វរសេនីយ៍ទោ	សៀង	សុខរ៉ា	អត្តលេខ ០៩៥០៣៩	នាយទាហានការពារផ្ទាល់
២៥-វរសេនីយ៍ទោ	ទ៉ោ	ផា	អត្តលេខ ១៥១៣៤៧	នាយទាហានការពារផ្ទាល់
២៦-វរសេនីយ៍ទោ	ម៉ៅ	ឡុង	អត្តលេខ ១៦២០៤៨	នាយទាហានការពារផ្ទាល់
២៧-វរសេនីយ៍ទោ	គា	ស៊ីណាត	អត្តលេខ ១៦២១៩២	នាយទាហានការពារផ្ទាល់
២៨-វរសេនីយ៍ទោ	និន	សុភក្រ្ត	អត្តលេខ ១៦០៦៧៥	នាយទាហានការពារផ្ទាល់
២៩-វរសេនីយ៍ទោ	ឈី	ភក្តី	អត្តលេខ ០២១០៧៦	នាយទាហានការពារផ្ទាល់
៣០-វរសេនីយ៍ទោ	ស៊ិន	សុវណ្ណ	អត្តលេខ ០១០២៥៧	នាយទាហានការពារផ្ទាល់
៣១-វរសេនីយ៍ទោ	គីម	ញ៉ី	អត្តលេខ ០៧៣៨៦៩	នាយទាហានការពារផ្ទាល់

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង បណ្តាសមាសភាពដូចក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៦០៧ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយសហមេត្រី

១៧

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់អនុប្រធានទី២ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ចំនួន ០១គ្រឿង ជូនលោក **តាកៅ អ៊ីវណ្ណា** (**Mr. Takao IWANA**) ជាទីប្រឹក្សាគោលនយោបាយរបស់ JICA ប្រចាំនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជ ផ្នែកជំរុញការវិនិយោគឯកជន ដែលក្នុងរយៈពេលបំពេញបេសកកម្មនៅកម្ពុជា លោកបានចូលរួមយ៉ាងសកម្មក្នុងការជួយ សម្របសម្រួលកិច្ចការជំរុញការវិនិយោគ ដោយបានបង្កបរិយាកាសជួយទំនាក់ទំនងរវាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជ និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន ស្ថានទូតជប៉ុន និងមជ្ឈមណ្ឌលអាស៊ានជប៉ុន ដើម្បីបង្កើនកិច្ចសហប្រ បត្តិការក្នុងការជំរុញការវិនិយោគជប៉ុន អោយមកវិនិយោគនៅព្រះរាជាណាចក្រកម្ពុជា ទទួលបានលទ្ធផលគួរជា ពេញចិត្ត ។

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អនុប្រធានទី២ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវអនុវត្តអនុក្រឹត នេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០០៩
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

៩-វរសេនីយ៍ទោ	កែវ	ពិសិដ្ឋ	អត្តលេខ ០០៥២៧៩	នាយទាហានការពារផ្ទាល់
១០-វរសេនីយ៍ទោ	ព្រហ្ម	ប៉ូរ៉ា	អត្តលេខ ០២១១៩២	នាយទាហានការពារផ្ទាល់
១១-វរសេនីយ៍ទោ	យ៉ន់	សារឿន	អត្តលេខ ០០៤០១៧	នាយទាហានការពារផ្ទាល់
១២-វរសេនីយ៍ទោ	ថៅ	គឿន	អត្តលេខ ០១១៧៦៨	នាយទាហានការពារផ្ទាល់
១៣-វរសេនីយ៍ទោ	ញៀម	រ៉ា	អត្តលេខ ១៧៩៤៧៣	នាយទាហានការពារផ្ទាល់
១៤-វរសេនីយ៍ទោ	ឡូន	វីរៈ	អត្តលេខ ១៣៤៦៧៨	នាយទាហានការពារផ្ទាល់
១៥-វរសេនីយ៍ទោ	ហែម	ឡុងគង់	អត្តលេខ ១៣៣៣១៩	នាយទាហានការពារផ្ទាល់
១៦-វរសេនីយ៍ទោ	ឃួន	សម្បត្តិ	អត្តលេខ ០៦១៨៤៦	នាយទាហានការពារផ្ទាល់
១៧-វរសេនីយ៍ទោ	អេង	ហ៊ី	អត្តលេខ ០១២៤៤៧	នាយទាហានការពារផ្ទាល់
១៨-វរសេនីយ៍ទោ	ធីម	ស៊ីណារត្ន	អត្តលេខ ១១៤២៩០	នាយទាហានការពារផ្ទាល់
១៩-វរសេនីយ៍ទោ	ម៉ែន	ហ៊ុយ	អត្តលេខ ០១១៧៥៩	នាយទាហានការពារផ្ទាល់
២០-វរសេនីយ៍ទោ	ម៉ាក	សារ៉ាត់	អត្តលេខ ០៤៣៨៩៩	នាយទាហានការពារផ្ទាល់
២១-វរសេនីយ៍ទោ	ញឹម	សាវឿន	អត្តលេខ ១៦៨០៦៤	នាយទាហានការពារផ្ទាល់
២២-វរសេនីយ៍ទោ	នួន	ណារិទ្ធ	អត្តលេខ ២៣២១៤៦	នាយទាហានការពារផ្ទាល់
២៣-វរសេនីយ៍ទោ	ចាន់	សំអាង	អត្តលេខ ០៤០៦៦៣	នាយទាហានការពារផ្ទាល់
២៤-វរសេនីយ៍ទោ	សឿង	សុខរ៉ា	អត្តលេខ ០៩៥០៣៩	នាយទាហានការពារផ្ទាល់
២៥-វរសេនីយ៍ទោ	ម៉ៅ	ផា	អត្តលេខ ១៥១៣៤៧	នាយទាហានការពារផ្ទាល់
២៦-វរសេនីយ៍ទោ	ម៉ៅ	ឡុង	អត្តលេខ ១៦២០៤៨	នាយទាហានការពារផ្ទាល់
២៧-វរសេនីយ៍ទោ	គា	ស៊ីណាត	អត្តលេខ ១៦២១៩២	នាយទាហានការពារផ្ទាល់
២៨-វរសេនីយ៍ទោ	និន	សុគន្ធ	អត្តលេខ ១៦០៦៧៥	នាយទាហានការពារផ្ទាល់
២៩-វរសេនីយ៍ទោ	លី	ឥទ្ធិ	អត្តលេខ ០២១០៧៦	នាយទាហានការពារផ្ទាល់
៣០-វរសេនីយ៍ទោ	ស៊ិន	សុវណ្ណ	អត្តលេខ ០១០២៥៧	នាយទាហានការពារផ្ទាល់
៣១-វរសេនីយ៍ទោ	គីម	ញ៉ី	អត្តលេខ ០៧៣៨៦៩	នាយទាហានការពារផ្ទាល់

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង បណ្តាសមាសភាពដូចក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ៩ ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ១៧០៧.អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

របស់

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ មេបញ្ជាការកងទ័ពជើងគោក

សម្រេច

មាត្រា១ ៈ-

ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូននាយទាហាន និង នាយទាហានរង ចំនួន៦៦ រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ច បំរើជាតិ មាតុភូមិ កន្លងមក ដូចមានរាយនាមខាងក្រោម ÷

ក-មេដាយមាសការងារ ៈ

១	វរសេនីយ៍ទោ	ខែម សារ៉ុម	០១០៦៩៤	នាយរង ការិយាល័យហិរញ្ញវត្ថុ យោធភូមិភាគទី ៥
២	វរសេនីយ៍ទោ	សារី ហុក្របឹត	០២០៥៦៦	នាយរង ការិយាល័យទី ២ យោធភូមិភាគទី ៥
៣	វរសេនីយ៍ទោ	ឆែម សាខុន	០២៣០៤៩	នាយការិយាល័យហិរញ្ញវត្ថុ កងពលតូចថ្មើរជើងលេខ ៥២
៤	វរសេនីយ៍ត្រី	ម៉ូត អង្គារ៉ា	០២៨៨២៧	នាយផ្នែក លេខាធិការដ្ឋាន ការិយាល័យអភិវឌ្ឍន៍
៥	អនុសេនីយ៍ឯក	អ៊ុំ ហឿន	០៣៣៨៥៧	ជំនួយការការិយាល័យហិរញ្ញវត្ថុ យោធភូមិភាគទី ៥
៦	អនុសេនីយ៍ឯក	អួន សុគន្ធា	០៤៦៥៥៦	ជំនួយការការិយាល័យហិរញ្ញវត្ថុ យោធភូមិភាគទី ៥
៧	អនុសេនីយ៍ឯក	ម៉ៅ សារ៉ុម	០៣០១៦៦	ជំនួយការ ហិរញ្ញវត្ថុលេខាធិការដ្ឋាន យោធភូមិភាគទី ៥
៨	អនុសេនីយ៍ឯក	គឹម សំអឿន	០៤៧២៥០	ជំនួយការ ហិរញ្ញវត្ថុវរសេនាតូចស៊ើបការណ៍យោធភូមិភាគទី ៥
៩	អនុសេនីយ៍ឯក	កែវ មករា	០៩៤១៩២	ជំនួយការ បុគ្គលិក មន្ទីរពេទ្យ យោធភូមិភាគទី ៥
១០	អនុសេនីយ៍ឯក	ម៉ី ឧុធ	០៣៣៨៤២	ជំនួយការហិរញ្ញវត្ថុ វរសេនាតូចវិស្វកម្ម យោធភូមិភាគទី ៥
១១	អនុសេនីយ៍ឯក	សូ ហាន	០៥៥៣៥៥	ជំនួយការ ហិរញ្ញវត្ថុ កងការពារព្រំដែនលេខ ៥០១

១២	អនុសេនីយ៍ឯក	ជួន សីហា	០៣៧៥៥៨	ជំនួយការ ហិរញ្ញវត្ថុ កងការពារព្រំដែនលេខ ៥០២
១៣	អនុសេនីយ៍ឯក	ផាត ឆៀង	០៣៥៣៣៥	ជំនួយការ ហិរញ្ញវត្ថុ កងពលតូចថ្មើរជើងលេខ ៥២
១៤	អនុសេនីយ៍ឯក	សុខ ស្មើ	០៣០៣៩៤	បេឡា ហិរញ្ញវត្ថុ កងពលតូចថ្មើរជើងលេខ ៥៣
១៥	អនុសេនីយ៍ឯក	នឹម ណើរ	០៤២១២៨	ជំនួយការហិរញ្ញវត្ថុ វ.តូច ១ កងពលតូចថ្មើរជើងលេខ ៥៣
១៦	អនុសេនីយ៍ឯក	ស្វ សំអាត	០១៥៩៥៦	ជំនួយការហិរញ្ញវត្ថុ វ.តូច ៥៣២ កងពលតូចថ្មើរជើងលេខ៥៣
១៧	អនុសេនីយ៍ឯក	គាត ឆុន	០៥៣៩៨០	ជំនួយការហិរញ្ញវត្ថុ វ.តូច ៥៣៣ កងពលតូចថ្មើរជើងលេខ៥៣
១៨	អនុសេនីយ៍ឯក	ចាន់ សឿន	០៣២៧៤៨	ជំនួយការហិរញ្ញវត្ថុ វ.តូច ៥៣៣ កងពលតូចថ្មើរជើងលេខ៥៣
១៩	អនុសេនីយ៍ឯក	ទេព មានជុន្នី	០៧៦៥០៩	ជំនួយការហិរញ្ញវត្ថុ តំបន់ប្រតិបត្តិការសឹករងពោធិសាត់
២០	អនុសេនីយ៍ឯក	សោម ឈយន	០៥៥៥១៤	ជំនួយការហិរញ្ញវត្ថុ តំបន់ប្រតិបត្តិការសឹករងប៉ៃលិន
២១	អនុសេនីយ៍ឯក	ហ៊ុយ ទិចិត្រ	០២២០៤៧	ជំនួយការហិរញ្ញវត្ថុ វ.ត៥០៧ តំបន់ប្រតិបត្តិការសឹករងប៉ៃលិន
២២	អនុសេនីយ៍ឯក	តាត ទិត	០៥៥០៧០	នាយរង ហិរញ្ញវត្ថុ តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
២៣	អនុសេនីយ៍ឯក	កៅ សារិន	០៣០៨៤០	ជំនួយការ ហិរញ្ញវត្ថុ តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
២៤	អនុសេនីយ៍ឯក	ស៊ឹម សោម	០៤៤៣២៥	នាយរងអគាររបួស មន្ទីរពេទ្យសំពៅលូន យោធភូមិភាគទី ៥
២៥	អនុសេនីយ៍ឯក	លី តុលា	០៤៨៥១៣	នាយរងផ្នែកលេខាធិការដ្ឋាន ការិយាល័យអភិវឌ្ឍន៍
២៦	អនុសេនីយ៍ឯក	លឹម ហេង	១៥៧៧៣០	ជំនួយការផ្នែកលេខាធិការដ្ឋាន ការិយាល័យអភិវឌ្ឍន៍
២៧	អនុសេនីយ៍ឯក	អេង ហួត	១៣៤៦៤៨	ជំនួយការផ្នែកលេខាធិការដ្ឋាន ការិយាល័យអភិវឌ្ឍន៍
២៨	អនុសេនីយ៍ឯក	អ៊ុង ទិរៈ	២០១២៦១	ជំនួយការផ្នែកលេខាធិការដ្ឋាន ការិយាល័យអភិវឌ្ឍន៍
២៩	អនុសេនីយ៍ឯក	ទឹម ឆេងលី	០២៨៩៤៨	នាយរងផ្នែកទំនាក់ទំនង ការិយាល័យអភិវឌ្ឍន៍
៣០	អនុសេនីយ៍ទោ	សុខ គន្ធី	០៩៤៥១២	ជំនួយការការិយាល័យហិរញ្ញវត្ថុ យោធភូមិភាគទី ៥
៣១	អនុសេនីយ៍ទោ	ផាត់ ចំនួសុភ័ក្រ	២២៧៩៣៤	ជំនួយការហិរញ្ញវត្ថុ លេខាធិការដ្ឋាន យោធភូមិភាគទី ៥
៣២	អនុសេនីយ៍ទោ	ឃី យឿន	០៣០៣៣៧	ជំនួយការហិរញ្ញវត្ថុ កងពលតូចថ្មើរជើងលេខ ៥៣
៣៣	អនុសេនីយ៍ទោ	ពិន សុរិយា	០៧៦៥០៨	ជំនួយការហិរញ្ញវត្ថុ វ.តូច១ តំបន់ប្រតិបត្តិការសឹករងពោធិសាត់
៣៤	អនុសេនីយ៍ទោ	នាក់ សាលីន	១៣៣១៨២	ជំនួយការហិរញ្ញវត្ថុ ផ្នែកសឹករងសាលាក្រៅ តំ.សឹករងប៉ៃលិន
៣៥	អនុសេនីយ៍ទោ	ម៉ី សុវណ្ណា	០៥៥២២៧	ជំនួយការហិរញ្ញវត្ថុ វ.តូច ១ តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៣៦	អនុសេនីយ៍ទោ	មូ តូ	០៣២៨៣២	ជំនួយការហិរញ្ញវត្ថុ ផ្នែកសឹករងកំរៀង តំ.សឹករងពោធិសាត់
៣៧	អនុសេនីយ៍ទោ	ខួន សេងហាក់	០៧៦៥១២	ជំនួយការហិរញ្ញវត្ថុ កងការពារព្រំដែនលេខ ៥០១
៣៨	អនុសេនីយ៍ត្រី	ស្រី រិទ្ធី	០៤២០៧២	ជំនួយការហិរញ្ញវត្ថុ តំបន់អភិវឌ្ឍន៍ យោធភូមិភាគទី ៥
៣៩	អនុសេនីយ៍ត្រី	អ៊ឹម រ៉ាឌី	១៧៨៨២១	ជំនួយការហិរញ្ញវត្ថុ កងការពារព្រំដែនលេខ ៥០៤
៤០	អនុសេនីយ៍ត្រី	យុត សុភ័ណ្ឌ	០៥៥១១១	ជំនួយការហិរញ្ញវត្ថុ វ.តូច ៣ តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៤១	អនុសេនីយ៍ត្រី	សុ ភិរម្យ	០៧៧១៤៦	ជំនួយការហិរញ្ញវត្ថុ ផ្នែកសឹករងសំឡូត តំ.សឹករងបាត់ដំបង

ខ-មេដាយប្រាក់ការងារ :

១	វរសេនីយ៍ត្រី	សុខ ថេង	០២៣១៤៣	ជំនួយការការិយាល័យយោធាតំបន់ យោធភូមិភាគទី ៥
២	អនុសេនីយ៍ឯក	យន់ គឿន	២២៨៩២២	ជំនួយការការិយាល័យអភិវឌ្ឍន៍ យោធភូមិភាគទី ៥

៣	អនុសេនីយ៍ឯក	ហេង សុធា	០៦១៩៨២	ជំនួយការការិយាល័យអភិវឌ្ឍន៍ យោធភូមិភាគទី ៥
៤	អនុសេនីយ៍ឯក	ឈួយ ឆាយ	០៣៧០៨០	ជំនួយការ ហិរញ្ញវត្ថុ មន្ទីរពេទ្យ យោធភូមិភាគទី ៥
៥	អនុសេនីយ៍ឯក	រ៉ុង សុភង	០១២៦៦២	ជំនួយការហិរញ្ញវត្ថុ កងពលតូចថ្មើរជើងលេខ ៥២
៦	អនុសេនីយ៍ឯក	ម៉ី យ៉ុង	០៥២៧៧២	ជំនួយការហិរញ្ញវត្ថុ វ.តូច ៥៣២ កងពលតូចថ្មើរជើងលេខ៥៣
៧	អនុសេនីយ៍ឯក	ម៉ុយ មេង	០៣២៧៩៥	ជំនួយការហិរញ្ញវត្ថុ វ.តូច ៥៣៤ កងពលតូចថ្មើរជើងលេខ៥៣
៨	អនុសេនីយ៍ទោ	ផាន់ ផា	០៤២១៩៦	ជំនួយការ ហិរញ្ញវត្ថុ កងពលតូចថ្មើរជើងលេខ ៥១
៩	អនុសេនីយ៍ទោ	អ៊ុង រឿត	០២២១៥៨	ជំនួយការហិរញ្ញវត្ថុ វ.តូច ៥២៣ កងពលតូចថ្មើរជើងលេខ៥២
១០	អនុសេនីយ៍ទោ	យុត យឿ	០៥៥២១១	ជំនួយការ ហិរញ្ញវត្ថុ កងការពារព្រំដែនលេខ ៥០២
១១	អនុសេនីយ៍ត្រី	ទេព វិសាល	០៧៣៥៣៣	ជំនួយការ ហិរញ្ញវត្ថុ កងពលតូចថ្មើរជើងលេខ ៥៣
១២	អនុសេនីយ៍ត្រី	ស៊ុយ សំមុន្នី	០៣២៩៧២	ជំនួយការ ហិរញ្ញវត្ថុ ផ្នែកសឹករងប៉ៃលិន ត.សឹករងប៉ៃលិន
១៣	អនុសេនីយ៍ត្រី	យស់ រី	០៣២៧៥៣	ជំនួយការ ហិរញ្ញវត្ថុ ផ្នែកសឹករងភ្នំព្រឹក ត.សឹករងបាត់ដំបង
១៤	នាយចំណង់	ខែម ថាន្នី	១៧៨៤៦៨	ជំនួយការ ហិរញ្ញវត្ថុ វ.តូចរថក្រោះ យោធភូមិភាគទី ៥
១៥	នាយចំណង់	ទេស សុវុឌ្ឍា	០៥៥២៥៤	ជំនួយការហិរញ្ញវត្ថុ វ.តូច៥០៦ ត.សឹករងបាត់ដំបង

គ.មេដាយសិរីវឌ្ឍនភាពទាហាន :

១	អនុសេនីយ៍ឯក	អ៊ុក ណារិទ្ធ	០២៣២១៣	ជំនួយការហិរញ្ញវត្ថុ វ.តូចវិស្វកម្ម យោធភូមិភាគទី ៥
២	អនុសេនីយ៍ឯក	អ៊ាង គីមហ៊ាត	០៣០១៨២	ជំនួយការ ការិយាល័យទី ៣ យោធភូមិភាគទី ៥
៣	អនុសេនីយ៍ឯក	ស៊ឿម យ៉ឿប	០២១៣៧២	ជំនួយការ ផ្នែករថក្រោះ យោធភូមិភាគទី ៥
៤	អនុសេនីយ៍ទោ	ថូ សារ៉ាត់	០៣៣០៨២	ជំនួយការ ហិរញ្ញវត្ថុ លេខាធិការដ្ឋាន យោធភូមិភាគទី ៥
៥	អនុសេនីយ៍ទោ	មាស ទ្រី	០៣៣៧៧៥	ជំនួយការហិរញ្ញវត្ថុ វ.តូច ៥២២ កងពលតូចថ្មើរជើងលេខ៥២
៦	អនុសេនីយ៍ត្រី	ទុំត ចាន់	០៣២៨៥៥	ជំនួយការហិរញ្ញវត្ថុ វ.តូច ៥៣៤ កងពលតូចថ្មើរជើងលេខ៥៣
៧	អនុសេនីយ៍ត្រី	ប៊ុន ធឿន	០៣៣៦៨២	ជំនួយការហិរញ្ញវត្ថុ វ.តូច ៥២១ កងពលតូចថ្មើរជើងលេខ៥២
៨	អនុសេនីយ៍ត្រី	សាន ធីម	០៩០៩០៨	ជំនួយការហិរញ្ញវត្ថុ ផ្នែកសឹករងវាលវែង ត.សឹករងពោធិ៍សាត់
៩	នាយចំណង់	សុខ សារិទ្ធ	១៦០៦៨១	ជំនួយការហិរញ្ញវត្ថុ វ.តូច ៥២៤ កងពលតូចថ្មើរជើងលេខ៥២
១០	នាយចំណង់	ជា សម្បត្តិ	១១១៦២៣	ជំនួយការហិរញ្ញវត្ថុ ផ្នែកសឹករងសំពៅលូន ត.សឹករងបាត់ដំបង

មាត្រា២ :-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និង មេបញ្ជាការកងទ័ពជើងគោក ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ២
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៧០៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.—

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ប្រគេន និងផ្តល់ជូនមន្ត្រីរាជការក្រុមការងារ និងសប្បុរសជនចំនួន ១៦រូប ដែលបានលះបង់កំលាំងកាយចិត្ត និងបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាង និងអភិវឌ្ឍន៍មូលដ្ឋានភូមិឃុំ និងសមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា និងហេដ្ឋារចនាសម្ព័ន្ធតមនាគមន៍ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

១- ព្រះតេជគុណ **រស់ ឌី** ព្រះវិន័យធរគណខេត្តស្វាយរៀង បច្ច័យចំនួន ៤៣.៧០០ ដុល្លារ

២-ព្រះតេជគុណ **ឆូ វណ្ណា** ព្រះចៅអធិការវត្តសំរោង បច្ច័យចំនួន ៤៣.០០០ ដុល្លារ

៣-លោក **គង់ ម៉ិនថន** មន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ថវិកាចំនួន ៥៥.៥០០ ដុល្លារ

៤-លោកវរសេនីយ៍ទោ **នឹម តេខ** អត្តលេខ ០២៨៧២៥ មេបញ្ជាការសឹករង ក្រុងបារិត ថវិកាចំនួន ៥៥.០០០ ដុល្លារ

៥-លោកអនុសេនីយ៍ឯក **សយ ហុងម៉េង** អត្តលេខ ០៣៣៧៦ នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិបាវិត ថវិកាចំនួន ៥៤.៥០០ ដុល្លារ

៦-លោកអនុសេនីយ៍ឯក គា ធី អត្តលេខ ៩៤៩៩០ នាយរងការិយាល័យ នាយកដ្ឋានការពារបិតិកភ័ណ្ឌជាតិ ក្រសួងមហាផ្ទៃ ថវិកាចំនួន ៤៧.០០០ ដុល្លារ

៧-ឯកឧត្តម ឃិន លន ទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ថវិកាចំនួន ៤៥.៥០០ ដុល្លារ

៨-លោក សោម មុន្នី មន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ថវិកាចំនួន ៤៥.២០០ ដុល្លារ

៩-លោកអនុសេនីយ៍ឯក គៅ សំអាន អត្តលេខ ០៣៦៦៨៥ នាយរងការិយាល័យ ក្រសួងការពារជាតិ ថវិកាចំនួន ៤៤.៥០០ ដុល្លារ

១០-លោកអនុសេនីយ៍ទោ សោម សារិទ្ធ អត្តលេខ ៣៨២៥៨ មន្ត្រីប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិបាវិត ថវិកាចំនួន ៤៣.៥០០ ដុល្លារ

១១-លោកវរសេនីយ៍ត្រី រឹម លឹមសេង អត្តលេខ ៩៧៩៥៥ នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិក្អមសំណរ កោះរកា ថវិកាចំនួន ៤៣.០០០ ដុល្លារ

១២-លោកវរសេនីយ៍ឯក លួន គឹមហេង អត្តលេខ ០១៦៥០៨ នាយរងការិយាល័យ ក្រសួងការពារជាតិ ថវិកាចំនួន ៤២.៦០០ ដុល្លារ

១៣-លោក ឃូ ចាន់ធូ សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ៤២.០០០ ដុល្លារ

១៤-លោកស្រី មួង ផុន សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ៤១.០០០ ដុល្លារ

១៥-លោកស្រី នាយ ឃីម សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ៤០.៥០០ ដុល្លារ

១៦-លោក នី សេង សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ៤០.៥០០ ដុល្លារ

មាត្រា ២ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តស្វាយរៀង និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ១៦០៤..អនក្រ.ត៥

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.—

ត្រូវបានបំពាក់ **មេដាយមាសការងារ** ផ្តល់ជូនមន្ត្រីរាជការក្រុមការងារ និងសប្បុរសជនចំនួន ២០រូប ដែលបានលះបង់កំលាំងកាយចិត្ត និងបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងនិងអភិវឌ្ឍន៍មូលដ្ឋានភូមិឃុំ និងសមិទ្ធផលនានាក្នុងវិស័យ ព្រះពុទ្ធសាសនា និងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ដែលមានរាយនាមដូចខាងក្រោម :

១-លោក **ម៉ុល ម៉ុនថា**	មន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
២-លោក **សេខ ទណ្ឌរដេត**	មន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
៣-លោក **កែប នា**	មន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
៤-លោក **គង់ សារឿន**	មន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
៥-លោក **ម៉ុន ពៅ**	មន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
៦-លោកអនុសេនីយ៍ឯក **ខួន ធីរៈ**	អត្តលេខ ១៣១៩០១ នាយរងលេខាធិការ អគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងការពារជាតិ
៧-លោក **ម៉ែន ស៊ីថា**	មន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
៨-លោក **សាំង សុខា**	មន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៩-លោកស្រី ឌុំ សារិទ្ធិដា មន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

១០-លោក សែន សុខុម មន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

១១-លោក នុត លីនួយ មន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

១២-លោក ជា សំណាង សប្បុរសជននៅខេត្តតាកែវ

១៣-លោក គោរគ ទ៉ាន់ថន មន្ត្រីក្រសួងសុខាភិបាល

១៤-លោក ស្រី កុម្ភារ មន្ត្រីក្រសួងសុខាភិបាល

១៥-លោក ទ៉ា សុវណ្ណពិសាល មន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១៦-លោកវរសេនីយ៍ឯក ស៊ូនី វឌ្ឍទិសិដ្ឋ អត្តលេខ ០៤១៥៦៥ នាយករងទីចាត់ការការពារគីមីសាស្ត្រ ក្រសួងការពារជាតិ

១៧-លោកអនុសេនីយ៍ឯក ឆេត ស៊ីផារ៉ាណា នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិបាវិត អត្តលេខ ១២៩៨៦

១៨-ព្រឹទ្ធាចារ្យ ម៉ៅ គឿន សប្បុរសជននៅរាជធានីភ្នំពេញ

១៩-លោកវរសេនីយ៍ត្រី អ៊ុំ សំណាង អត្តលេខ ០៨៨៩៩ នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិ ក្អមសំណរ កោះរកា

២០-លោកវរសេនីយ៍ត្រី កែវ សាម៉ុឌី អត្តលេខ០៧០៣៩ នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិ ក្អមសំណរ កោះរកា

មាត្រា ២ .—

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តស្វាយរៀង និង សាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៧. សសរ

សេចក្តីសម្រេច

ស្តីពី

ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសម្របសម្រួល និងដោះស្រាយបញ្ហាវិវាទនៅក្នុងគម្រោងវិនិយោគអភិវឌ្ឍន៍ របស់ក្រុមហ៊ុន UNION DEVELOPMENT GROUP Co.,Ltd ខេត្តកោះកុង

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចកក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩១/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៥៧អនក្រ/បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពី ការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញសេចក្តីសម្រេចលេខ ០៨ សសរ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៩ ស្តីពីការការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសម្របសម្រួល និងដោះស្រាយបញ្ហាវិវាទនៅក្នុងគម្រោងវិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុន UNION DEVELOPMENT GROUP CO., LTD នៅខេត្តកោះកុង និងគម្រោងវិនិយោគអភិវឌ្ឍន៍ក្នុងតំបន់ការពារធម្មជាតិ ទូទាំងប្រទេស
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

ស ម្រេ ច

ប្រការ១: បង្កើតគណៈកម្មការអន្តរក្រសួងមួយ ដើម្បីសម្របសម្រួល និងដោះស្រាយវិវាទ នៅក្នុងគម្រោងវិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុនUNION DEVELOPMENT GROUP CO., LTD នៅខេត្តកោះកុង ដែលមានសមាសភាពដូចខាងក្រោម:

១- ឯកឧត្តមបណ្ឌិត **ម៉ុក ម៉ារ៉េត**	ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន	ប្រធាន
២- ឯកឧត្តម នាយឧត្តមសេនីយ៍ **គន់ គីម**	អគ្គមេបញ្ជាការរង និងជានាយសេនាធិការចម្រុះ នៃកងយោធពលខេមរភូមិន្ទ	អនុប្រធាន
៣- ឯកឧត្តម **សុខ ចិន្តា**	រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា	អនុប្រធាន
៤- ឯកឧត្តម **ចៅ សុវណ្ណា**	រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការក្រសួងយុត្តិធម៌	អនុប្រធាន
៥- ឯកឧត្តម **នាន់ សាវ៉ាន**	រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	អនុប្រធាន
៦- ឯកឧត្តម **ទឹក គ្រឿនវុត្ថា**	រដ្ឋលេខាធិការ ក្រសួងបរិស្ថាន	អនុប្រធាន
៧- ឯកឧត្តម **ប៊ុន លើត**	អភិបាល នៃគណៈអភិបាលខេត្តកោះកុង	អនុប្រធានអចិន្ត្រៃយ៍
៨- ឯកឧត្តម **សួរ ឌិចឆ័រ**	រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៩- ឯកឧត្តម **អ៊ិត សុខុន**	រដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	សមាជិក
១០- ឯកឧត្តម **ម៉ុល លឹម**	រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ	សមាជិក
១១- ឯកឧត្តម **ហ៊ីង ថូរ៉ាក់ស៊ី**	រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
១២- ឯកឧត្តម **ឡុង នរិន្ទ**	មេធាវីរាជរដ្ឋាភិបាលកម្ពុជា	សមាជិក
១៣- ឯកឧត្តម ឧត្តមសេនីយ៍ឯក **ទេព្យ ពិសេន**	មេបញ្ជាការរង និងជានាយសេនាធិការកងរាជអាវុធហត្ថលើផ្ទៃប្រទេស	សមាជិក
១៤- ឯកឧត្តម **ជួន សុវណ្ណ**	អគ្គស្នងការរងនគរបាលជាតិ	សមាជិក
១៥- លោក **សៅ ដល្លា**	តំណាងអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី	សមាជិក
១៦- ឯកឧត្តម **ចាយ សាមិត្ត**	ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន	លេខាធិការ

ប្រការ២: គណៈកម្មការអន្តរក្រសួងនេះ មានតួនាទីភារកិច្ច និងបេសកកម្មដូចតទៅ:

១- ធ្វើការសម្របសម្រួល និងដោះស្រាយបញ្ហាវិវាទ នៅលើទីតាំងគម្រោងវិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុន UNION DEVELOPMENT GROUP CO., LTD

២- ចូលរួមពិភាក្សា ផ្តល់យោបល់ លើការងារអភិរក្ស និងអភិវឌ្ឍន៍ក្នុងគម្រោងវិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុន UNION DEVELOPMENT GROUP CO., LTD

៣- ចូលរួមពិភាក្សា ផ្តល់យោបល់ និងដោះស្រាយលើរាល់ទម្រង់ប័ណ្ណសម្គាល់សិទ្ធិ និងលិខិតពាក់ព័ន្ធនឹងការកាន់កាប់ ប្រើប្រាស់ដីធ្លីក្នុងគម្រោងវិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុន UNION DEVELOPMENT GROUP CO., LTD

៤- លើកវិធានការទប់ស្កាត់ និងដោះស្រាយជាបន្ទាន់ នូវរាល់សកម្មភាពអនាធិបតេយ្យ ដែលកើតមានឡើងលើទីតាំងគម្រោងវិនិយោគរបស់ក្រុមហ៊ុន UNION DEVELOPMENT GROUP CO., LTD

ប្រការ៣: បណ្តាសមាជិកគណៈកម្មការអន្តរក្រសួង ដែលតំណាងឱ្យក្រសួង ស្ថាប័ន ខេត្ត ពាក់ព័ន្ធ ត្រូវចូលរួមទទួលខុសត្រូវ ក្នុងក្របខណ្ឌសមត្ថកិច្ច ភារកិច្ចដែលបានចែងក្នុងប្រការ២ខាងលើ និងត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធានគណៈកម្មការអន្តរក្រសួង ដើម្បីបូកសរុបលទ្ធផលការងារដែលសម្រេចបានជូនរាជរដ្ឋាភិបាល ។

ប្រការ៤: គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងបរិស្ថាន និងមានលេខាធិការមួយដែលមានទីតាំងនៅក្នុងក្រសួងបរិស្ថាន ។

ប្រការ៥: ទុកជានិរាករណ៍សេចក្តីសម្រេចលេខ ០៨ សសរ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៩ ស្តីពីការការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសម្របសម្រួល និងដោះស្រាយបញ្ហាវិវាទនៅក្នុងគម្រោងវិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុន UNION DEVELOPMENT GROUP CO., LTD នៅខេត្តកោះកុង និងគម្រោងវិនិយោគអភិវឌ្ឍន៍ក្នុងតំបន់ការពារធម្មជាតិ និងសេចក្តីសម្រេចណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ។

ប្រការ៦: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងយុត្តិធម៌ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស អគ្គស្នងការនគរបាលជាតិ អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្ត ដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ៦ "ដើម្បីជូនជ្រាប និងអនុវត្ត"
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០១២ សហវ.អគន

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ២០០៩

សេចក្តីជូនដំណឹង

ស្តីពី

វិធានការបំបាត់ការលួចបន្លំបោះពុម្ព ការធ្វើអាជីវកម្មជួញដូរ និង ការប្រើប្រាស់ប័ណ្ណក្លែងក្លាយសំរាប់បង់ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ ឆ្នាំ២០០៩

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានកិត្តិយសជំរាបជូនសាធារណជនទាំងអស់មេត្តាជ្រាបថា កន្លងមកនេះ មានជនខិលខូចមួយចំនួនបានលួចបន្លំបោះពុម្ពលក់ និងប្រើប្រាស់នូវប័ណ្ណក្លែងក្លាយសំរាប់បង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទឆ្នាំ២០០៩ នៅលើទីផ្សារក្នុងរាជធានីភ្នំពេញ និង ខេត្ត នានា ។

ក្នុងគោលបំណងទប់ស្កាត់អំពើល្មើសច្បាប់ខាងលើនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមធ្វើការបដិសេធមិនទទួលស្គាល់ប័ណ្ណក្លែងក្លាយលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះនេះឡើយ ។ ទន្ទឹមនេះដែរ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងចាត់វិធានការតាមច្បាប់រួមជាមួយក្រសួងមានសមត្ថកិច្ច ដើម្បីចាប់ឃាត់ទុកជនទាំងឡាយណាដែលបានលួចបន្លំបោះពុម្ព ធ្វើអាជីវកម្មលក់ដូរ និងប្រើប្រាស់ប័ណ្ណក្លែងក្លាយទាំងនេះ យកមកផ្តន្ទាទោសតាមមាត្រា១៣៦ នៃច្បាប់ស្តីពីសារពើពន្ធ ដែលបានចែងថា " ដោយមិនទាន់គិតដល់ទោសទណ្ឌផ្សេងទៀត បុគ្គលណាដែលបានប្រព្រឹត្តអំពើរាំងស្ទះដល់ការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ ដូចមានចែងក្នុងមាត្រា១២៨ នៃច្បាប់នេះ ត្រូវរងការផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០រៀល (ប្រាំលានរៀល) ដល់ ១០.០០០.០០០រៀល(ដប់លានរៀល) ឬជាប់ពន្ធនាគារពី ១ខែ ដល់ ១ឆ្នាំ ឬទោសទាំងពីរនេះ " ។

ចាប់ពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៩ តទៅ អង្គភាពពន្ធដារនឹងធ្វើការត្រួតពិនិត្យផាកពិន័យចំនួនមួយដងស្មើប្រាក់ពន្ធ បន្ថែមលើប្រាក់ពន្ធដែលត្រូវបង់ចំពោះមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទទាំងឡាយណាដែលមិនបានបង់ពន្ធសំរាប់ឆ្នាំ២០០៩ ។ ចំពោះរថយន្ត ម្ចាស់យានយន្តត្រូវយកបង្កាន់ដៃបង់ពន្ធឆ្នាំ២០០៩ ដាក់តាមរថយន្តរបស់ខ្លួន ដើម្បីបង្ហាញជូនមន្ត្រីដែលមានសមត្ថកិច្ចត្រួតពិនិត្យនៅតាមចំណុចដៅមួយចំនួន ។

សេចក្តីដូចបានជំរាបជូនខាងលើ សូមសាធារណជនទាំងអស់មេត្តាជ្រាប និងចូលរួមបំបាត់អំពើល្មើសច្បាប់កុំបីខាន ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

បោះពុម្ពនៅអគ្គនាយកដ្ឋាន
រាជកិច្ច និង សេវាកុំព្យូទ័រ
នៃទីស្ដីការគណៈរដ្ឋមន្ត្រី